វិសុទ្ធិមគ្គ

សីលនិទ្ទេស និង ធុតង្គនិទ្ទេស

រៀបរៀងដោយ

ភិក្ខុ បញ្ញាបទីបោ ឡេង ធី

ព.ស. ២៥៥៩ គ.ស. ២០១៥

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

ខ្ញុំសូមនមស្ការចំពោះព្រះដ៏មានព្រះភាគ

ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ។

និទានគាថា

ទេវបញ្ហា

អន្តោជដា ពហិជដា ជដាយ ជដិតា បជា

តំ តំ គោតម បុច្ឆាមិ កោ ឥមំ វិជដយេ ជដំ ។

គ្រឿងចាក់ស្រែះខាងក្នុងក៏មាន គ្រឿងចាក់ស្រែះខាងក្រៅក៏មាន ពួកសត្វ ត្រូវគ្រឿងចាក់ស្រែះរួបរឹតហើយ បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គថា តើបុគ្គលណាអាចកាប់ឆ្ការនូវគ្រឿងចាក់ស្រែះនេះបាន ។

វិសុទ្ធិមគ្គ

ព្រះគាថា

សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ

អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ ។

នរជនណា ប្រកបដោយបញ្ញា មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានប្រាជ្ញាចាស់ក្លា ឃើញភ័យក្នុងវដ្តៈ កាលតាំងនៅស៊ប់ក្នុងសីលហើយអប់រំចិត្តចម្រើនបញ្ញា នរជននោះ អាចកាប់ឆ្ការនូវគ្រឿងចាក់ស្រែះ គឺតណ្ហានេះបាន ។

បរិយាយគាថា

សីលេ បតិដ្ឋាយាតិ សីលេ ឋត្វា ។ សីលំ បរិបូរយមានោ-យេវ ចេត្ថ សីលេ ឋិតោតិ វុច្ចតិ តស្មា សីលបរិបូរណេន សីលេ បតិដ្ឋហិត្វាតិ អយមេត្ថ អត្ថោ ។ ពីរបទថា **សីលេ បតិដ្ឋាយ** ប្រែថា តាំងនៅហើយក្នុងសីល ។ នរជន កាលញុំាង សីលឱ្យបរិបូណ៌ពេញលេញ ព្រះមានព្រះភាគត្រាស់ថា អ្នកតាំង នៅក្នុងសីល ព្រោះហេតុនោះ លោកអធិប្បាយថា អ្នកតាំងនៅ ហើយក្នុងសីល ដោយកិរិយាញុំាងសីលឱ្យបរិបូណ៌ ក្នុងពាក្យថា **សីលេ បតិដ្ឋាយ** នេះ ។ **នរោតិ សត្តោ** បទថា **នរោ** បានដល់ សត្វ ។ **សបញ្ញោតិ កម្មជតិហេតុកប្បដិសន្ធិប្បញ្ញាយ បញ្ញវា** បទថា **សបញ្ញោ** បានដល់ អ្នកមានបញ្ញា ដោយបញ្ញា តាំងពីកំណើតប្រកបដោយត្រៃហេតុកើតអំពីកម្ម ។

ចិត្តំ បញ្ញញ្ច ភាវយន្តិ សមាធិញ្ចេវ វិបស្សនញ្ច ភាវយ-មានោ ប្រយោគថា **ចិត្តំ បញ្ញញ្ច ភាវយំ** បានដល់ នរជន កាលចម្រើននូវសមាធិ និងវិបស្សនា ។ **អាតាបីតិ វីរិយវា.** បទថា **អាតាបី** បានដល់ អ្នកមានសេចក្តីព្យាយាម ។ **និបកោតិ នេបក្កំ វុច្ចតិ បញ្ញា, តាយ សមន្នាគតោតិ អត្ថោ.** បញ្ញាចាស់ក្លា ព្រះមានព្រះភាគត្រាស់ថា **និបកោ** អធិប្បាយថា

អ្នកប្រកបព្រមដោយនេបក្កបញ្ញានោះ ។ **ភិក្ខុតិ សំសារេ ភយំ ឥក្ខតីតិ ភិក្ខុ.** ពាក្យថា ភិក្ខុ មានវិគ្រោះថា (នរជន) អ្នកឃើញភ័យក្នុងសំសារវដ្ត ។

អធិប្បាយពាក្យថា វិសុទ្ធិមគ្គ

តត្ថ វិសុទ្ធីតិ សព្វមលវិរហិតំ អច្ចន្តបរិសុទ្ធំ និព្វានំ វេទិតព្វំ. ក្នុងពាក្យថា វិសុទ្ធិមគ្គនោះ ពាក្យថា វិសុទ្ធិ អ្នកសិក្សាគប្បីជ្រាបថាជាឈ្មោះនៃព្រះនិព្វាន ដែលប្រាសចាកមន្ទិលទាំង-ពួង ដែលបរិសុទ្ធដោយចំណែកមួយ ។ **តស្សា វិសុទ្ធិយា មគ្គោតិ វិសុទ្ធិមគ្គោ.** ផ្លូវនៃវិសុទ្ធិនោះ ឈ្មោះថា វិសុទ្ធិមគ្គ ។ **មគ្គោតិ អធិគមុបាយោ វុច្ចតិ.** ឧបាយជាហេតុឱ្យសម្រេច (នូវព្រះនិព្វាន) លោកហៅថា មគ្គ ។

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

ក្នុងកាលណា បុគ្គលឃើញដោយបញ្ញាថា សង្ខារទាំងពួងមិនទៀង ក្នុងកាលនោះ គេរមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

នត្ថិ ឈានំ អបញ្ញស្ស នត្ថិ បញ្ញា អឈាយិនោ
យម្ហិ ឈានញ្ច បញ្ញា ច ស វេ និព្វានសន្តិកេ ។

ឈាន រមែងមិនមានដល់បុគ្គលអ្នកឥតបញ្ញា បញ្ញា រមែងមិនមាន ដល់បុគ្គលអ្នកឥតឈាន ឈាន និងបញ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង លោកហៅថាអ្នកឋិតនៅជិតព្រះនិព្វាន ។

កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ

ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា ។

កម្ម វិជ្ជា ធម៌ សីល និងជីវិតដ៏ឧត្តម សត្វទាំងឡាយ រមែងបរិសុទ្ធ ដោយធម៌ទាំងនុ៎ះ មិនមែនដោយគោត្រ ឬដោយទ្រព្យទេ ។

សព្វទា សីលសម្បន្នោ បញ្ញវា សុសមាហិតោ

អារទ្ធវីរិយោ បហិតត្តោ ឱឃំ តរតិ ទុត្តរន្តិ ។

ភិក្ខុអ្នកមានបញ្ញា ដល់ព្រមដោយសីល មានចិត្តតាំងមាំល្អ ហើយប្រារព្ធសេចក្ដីព្យាយាម មានខ្លួនបញ្ជូនទៅហើយសព្វកាល រមែងឆ្លងនូវអន្លង់ដែលគេឆ្លងបានដោយកម្រ ។

*ក្នុងពាក្យថា បុគ្គលនោះអាចកាប់ឆ្ការនូវគ្រឿងចាក់ស្រែះនេះបាន បានដល់ អ្នកប្រកបព្រមដោយធម៌ ៦ ប្រការ គឺ ៖

១) សីល (**សីលេ បតិដ្ឋាយ**)

២) សមាធិ (**ចិត្តំ**)

៣) សជាតិប្បញ្ញា (**សបញ្ញោ**)

៤) វិបស្សនាបញ្ញា (**បញ្ញញ្ច**)

៥) បារិហារិកប្បញ្ញា (**និបកោ**)

៦) វីរិយៈ (**អាតាបី**)

* **ឯត្តាវតា ហិ.** សេចក្តីប៉ុណ្ណោះ ព្រះមានព្រះភាគប្រកាសគុណ ៩ យ៉ាង គឺ ៖

១. **តិស្សោ សិក្ខា** សិក្ខា ៣

២. **តិវិធកល្យាណំ សាសនំ** សាសនាមានលម្អ ៣

៣. **តេវិជ្ជតាទីនំ ឧបនិស្សយោ** ឧបនិស្ស័យនៃវិជ្ជា ៣ ជាដើម

៤. **អន្តទ្វយវជ្ជនមជ្ឈិមប្បដិបត្តិសេវនានិ** ការវៀរចាកផ្លូវអមពីរយ៉ាង និងសេពនូវមជ្ឈិមាបដិបទា

៥. **អបាយាទិសមតិក្កមុបាយោ** ឧបាយជាគ្រឿងកន្លងនូវគតិមានអបាយគតិជាដើម

៦. **តីហាការេហិ កិលេសប្បហានំ** កិរិយាលះបង់កិលេសដោយអាការ ៣ យ៉ាង

៧. **វីតិក្កមាទីនំ បដិបក្ខោ** ធម៌ជាបដិបក្ខចំពោះកិលេសមានវីតិក្កមកិលេសជាដើម

៨. **សង្កិលេសត្តយវិសោធនំ** កិរិយាជម្រះសង្កិលេស ៣ យ៉ាង (មានទុច្ចរិតសង្កិលេសជាដើម)

៩. **សោតាបន្នាទិភាវស្ស ច ការណំ** ហេតុនៃភាពជាព្រះអរិយបុគ្គល មានសោតាបន្នបុគ្គលជាដើម ។

សីលនិទ្ទេស

គាថាសម្តែងអានិសង្សរបស់សីល

សាសនេ កុលបុត្តានំ បតិដ្ឋា នត្ថិ យំ វិនា
អានិសំសបរិច្ឆេទំ តស្ស សីលស្ស កោ វទេ ។

ទីពឹងនៃកុលបុត្រទាំងឡាយក្នុងសាសនានេះ វៀរចាកសីលហើយ នឹងមានមកពីណា តើបុគ្គលណា អាចកំណត់នូវអានិសង្សរបស់សីលនោះបាន ។

បុច្ឆាវារៈ ៧ យ៉ាង

១. កឹ សីលំ អ្វីជាតួសីល ?

២. កេនដ្ឋេន សីលំ សីលដោយអត្ថថាដូចម្តេច ?

៣. កានស្ស លក្ខណរសប្បច្ចុបដ្ឋានបទដ្ឋានានិ
តើលក្ខណៈ កិច្ច អាការប្រាកដ និងហេតុជិតរបស់សីលដូចម្តេច ?

៤. កិមានិសំសំ សីលំ តើសីលមានអានិសង្សប៉ុន្មាន ?

៥. កតិវិធញ្ចេតំ សីលំ តើសីលមានប្រការប៉ុន្មាន ?

៦. កោ ចស្ស សង្កិលេសោ អ្វីជាគ្រឿងសៅហ្មងរបស់សីល ?

៧. កឹ វោទានំ អ្វីជាគ្រឿងផូរផង់របស់សីល ?

វិសជ្ជនាធារៈ

១) **កាំ សីលន្តិ ចាណាតិចាតាជីហិ វា វិរមន្តស្ស វត្តប្បដិបត្តឹ វា បូរេន្តស្ស ចេតនាទយោ ធម្មា ។** ធម៌ទាំងឡាយមានចេតនាជាដើមរបស់បុគ្គលកាលវៀរចាកទោសមានបាណាតិបាតជាដើមក្តី របស់បុគ្គលអ្នកបំពេញវត្តប្រតិបត្តិក្តី ឈ្មោះថា តួសីល ។

វុត្តញ្ហេតំ បដិសម្ភិទាយំ កាំ សីលន្តិ ចេតនា សីលំ ចេតសិកំ សីលំ សំវរោ សីលំ អវីតិក្កមោ សីលន្តិ ។ ក្នុងបដិសម្ភិទាមគ្គ ឆ្លើយសំនួរ **កាំ សីលំ** ថា ចេតនា ជាតួសីល ចេតសិក ជាតួសីល, សំវរៈ ជាតួសីល, អវីតិក្កមៈ ជាតួសីល ។

តត្ថ ចេតនាសីលំ នាម ចាណាតិចាតាជីហិ វា វិរមន្តស្ស វត្តប្បដិបត្តឹ វា បូរេន្តស្ស ចេតនា ។ ជំនុំតួសីលទាំងឡាយនោះ ចេតនា របស់បុគ្គលកាលវៀរចាកទោស មានបាណាតិបាតជាដើមក្តី របស់បុគ្គលអ្នកបំពេញវត្តប្រតិបត្តិក្តី ឈ្មោះថា ចេតនាសីល ។

ចេតសិកសីលំ នាម ចាណាតិចាតាជីហិ វិរមន្តស្ស វិរតិ ។ វិរតិរបស់បុគ្គលកាលវៀរចាកទោសទាំងឡាយ មានបាណាតិបាតជាដើម ឈ្មោះថា ចេតសិកសីល ។

អបិច ចេតនាសីលំ នាម បាណាតិបាតាទីនិ បជហន្តស្ស សត្តកម្មបថចេតនា ។ ន័យម្យ៉ាងទៀត ចេតនាក្នុងកុសលកម្មបថ ៧ របស់បុគ្គលកាលលះបង់នូវអកុសលកម្មទាំងឡាយ មានបាណាតិបាតជាដើម ឈ្មោះថា ចេតនាសីល ។ ចេតសិកសីលំ នាម អភិជ្ឈំ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតីតិ អាទិនា នយេន វុត្តា អនភិជ្ឈាអព្យាបាទសម្មាទិដ្ឋិធម្មា ។ អនភិជ្ឈា អព្យាបាទ និង សម្មាទិដ្ឋិទាំងឡាយ ដែលព្រះសាស្តាត្រាស់ទុកហើយ ដោយន័យជាដើមថា ភិក្ខុលះបង់អភិជ្ឈា មានចិត្តប្រាសចាកអភិជ្ឈា ហើយសម្រេចសម្រាន្តនៅដូច្នេះ ឈ្មោះថា ចេតសិកសីល ។ សំវរោ សីលន្តិ ឯត្ថ បញ្ចវិធេន សំវរោ វេទិតព្វោ បាតិមោក្ខសំវរោ សតិសំវរោ ញាណសំវរោ ខន្តិសំវរោ វីរិយសំវរោតិ ។ ក្នុងពាក្យថា សំវរៈជាសីលនោះ គប្បីជ្រាប សំវរៈ ដោយប្រការ ៥ គឺ បាតិមោក្ខសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។

តត្ថ ឥមិនា បាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុបេតោតិ អយំ បាតិមោក្ខសំវរោ ។ បណ្តាសំវរៈទាំង ៥ នោះ សំវរៈដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុជាអ្នក

ចូលដល់ហើយ ជាអ្នកប្រកបព្រមហើយ ដោយការសង្រួមក្នុងបាតិមោក្ខនេះដូច្នេះ នេះឈ្មោះថា បាតិមោក្ខសំវរៈ ។

រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតីតិ អយំ សតិសំវរោ ។ សំវរៈដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះរមែងរក្សានូវចក្ខុន្ទ្រិយ៍ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ៍ដូច្នេះ នេះឈ្មោះថា សតិសំវរៈ ។

យានិ សោតានិ លោកស្មឹ (**អជិតាតិ ភគវា**)
សតិ តេសំ និវារណំ សោតានំ សំវរំ ព្រូមិ
បញ្ញាយេតេ បិធិយ្យរេតិ អយំ ញាណសំវរោ ។

សំវរៈដែលព្រះមានព្រះភាគត្រាស់ថា ម្នាលអជិតៈ ក្រសែ (នៃតណ្ហា) ទាំងឡាយណាក្នុងលោក សតិជាគ្រឿងរារាំងនូវក្រសែទាំងឡាយនោះ តថាគត ពោលនូវការបិទក្រសែទាំងឡាយឯក្រសែទាំងឡាយនោះ បុគ្គលបិទបានដោយបញ្ញា នេះឈ្មោះថា ញាណសំវរៈ ។ **បច្ចយប្បដិសេវនម្បិ ឯត្ថេវ សមោធានំ គច្ឆតិ** ។ សូម្បីការសេពបច្ច័យ (ដោយឧបាយនៃប្រាជ្ញា) រមែងដល់នូវការប្រជុំចុះក្នុងញាណសំវរៈនោះដែរ ។

យោ បនាយំ ខមោ ហោតិ សីតស្ស ឧណ្ហស្សាតិ អាទិនា នយេន អាគតោ អយំ ខន្តិសំវរោ នាម ។

សំវរៈដែលមកហើយដោយន័យជាអាទិ៍ថា ភិក្ខុ ជាអ្នកអត់ទ្រាំចំពោះត្រជាក់និងក្តៅដូច្នេះ នេះឈ្មោះថា ខន្តិសំវរៈ ។

យោ ចាយំ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតីតិ អាទិនា នយេន អាគតោ អយំ វីរិយសំវរោ នាម ។ សំវរៈដែលមកហើយដោយន័យជាអាទិ៍ថា ភិក្ខុមិនព្រមទទួលនូវកាមវិតក្កៈដែលកើតឡើងហើយដូច្នេះ នេះឈ្មោះថា វីរិយសំវរៈ ។

អាជីវបារិសុទ្ធិបិ ឯត្ថេវ សមោធានំ គច្ឆតិ ។ សូម្បីអាជីវបារិសុទ្ធិសីល ក៏ដល់នូវការប្រជុំចុះ ក្នុងវីរិយសំវរៈនោះដែរ ។

ឥតិ អយំ បញ្ចវិធោបិ សំវរោ យា ច បាបភីរុកានំ កុលបុត្តានំ សម្បត្តវត្ថុតោ វិរតិ សព្វម្បេតំ សំវរសីលន្តិ វេទិតព្វំ ។ សំវរៈទាំង ៥ នេះក្តី ការវៀរចាកវត្ថុដែលខ្លួនជួបប្រទះនៃកុលបុត្រទាំងឡាយអ្នកខ្លាចបាបឯណាក្តី គុណជាតនោះសូម្បីទាំងអស់ គប្បីជ្រាបថាជាសំវរសីល ។

អវីតិក្កមោ សីលន្តិ សមាទិន្នសីលស្ស កាយិកវាចសិកោ អនតិក្កមោ ។ ការមិនប្រព្រឹត្តកន្លងតាមផ្លូវកាយ និងផ្លូវវាចា របស់បុគ្គលដែលបានសមាទានសីលហើយ ឈ្មោះថា អវីតិក្កមសីល ។

២) **កេនដ្ឋេន សីលន្តិ សីលនដ្ឋេន សីលំ ។** ឆ្លើយសំនួរ

កេនដ្ឋេន សីលំ ថា សីល ដោយអត្ថថា ប្រក្រតី ។

ក) **សមាធានំ វា កាយកម្មាទីនំ សុសីល្យវសេន អវិប្បកិណ្ណតាតិ អត្ថោ** ។ សីល (មានប្រក្រតី) រួបរួមទុកនូវកាយកម្មវចីកម្ម អធិប្បាយថា រួបរួមទុកមិនឱ្យរាត់រាយ ដោយអំណាចនៃសីលជាសីលល្អ ។

ខ) **ឧបធារណំ វា កុសលានំ ធម្មានំ បតិដ្ឋានវសេន អាធារភាវោតិ អត្ថោ** ។ សីល (មានប្រក្រតី) ទ្រទ្រង់ទុកនូវធម៌ទាំងឡាយជាកុសល អធិប្បាយថា ទ្រទ្រង់ទុកយ៉ាងមាំ ដោយអំណាចសីលតាំងនៅស៊ប់ ។

៣) **ឥធានិ កានស្ស លក្ខណរសប្បច្ចុបដ្ឋានបទដ្ឋានានីតិ ឯត្ថ** ។ ឆ្លើយសំនួរ **កានស្ស លក្ខណរសប្បច្ចុបដ្ឋានបទដ្ឋានានិ** ថា:

១. **សីលនលក្ខណំ** សីលមានប្រក្រតីជាលក្ខណៈ ,

២. **ទុស្សីល្យវិទ្ធំសនរសំ** មានកិរិយាកម្ចាត់នូវភាពទ្រុស្តសីលជាកិច្ច ,

៣. **សោចេយ្យប្បច្ចុបដ្ឋានំ** មានសេចក្តីស្អាតកាយវាចាចិត្តជាអាការប្រាកដ ,

៤. **ហិរិឱត្តប្បបទដ្ឋានំ** មានហិរិនិងឱត្តប្បៈ ជាហេតុជិត ។

៤) **កិមានិសំសំ សីលន្តិ អវិប្បដិសារាទិអនេក-គុណប្បដិលាភានិសំសំ** ។ ឆ្លើយសំនួរ **កិមានិសំសំ សីលំ** ថា សីលមានអានិសង្សជាអនេក មានសេចក្តីមិនក្តៅក្រហាយចិត្តជាខាងដើម មានអនុបាទាបរិនិព្វានជាខាងចុង ។

៥) **កតិវិធញ្ចេតំ សីលន្តិ តត្រិទំ វិសជ្ជនំ** ។ ចម្លើយក្នុងសំនួរ **កតិវិធញ្ចេតំ សីលំ** ថា សីលមាន ៥ ប្រការ ។

ប្រការ ១ ឯកសីល

សព្វមេវ តាវ ឥទំ សីលំ អត្តនោ សីលនលក្ខណេន ឯកវិធំ ។ សីលទាំងអស់ ដោយលក្ខណៈរបស់ខ្លួន មានតែមួយ គឺមានប្រក្រតីជាលក្ខណៈ ។

ប្រការ ២ ទុកសីល ៧ គូ

១. **ចារិត្តវារិត្តវសេន** ដោយចារិត្តសីល និង វារិត្តសីល ។

២. **អភិសមាចារិកអាទិព្រហ្មចរិយកវសេន** ដោយអភិ-សមាចារិកសីល និង អាទិព្រហ្មចរិយកសីល ។

៣. **វិរតិអវិរតិវសេន** ដោយវិរតិសីល និង អវិរតិសីល ។

៤. **និស្សិតានិស្សិតវសេន** ដោយនិស្សិតសីល និងអនិស្សិត-សីល ។

៥. **កាលបរិយន្តអាបាណកោដិកវសេន** ដោយកាល-បរិយន្តសីល និង អាបាណកោដិកសីល ។

៦. **សបរិយន្តាបរិយន្តវសេន** ដោយសបរិយន្តសីល និង អបរិយន្តសីល ។

៧. **លោកិយលោកុត្តរវសេន** ដោយលោកិយសីល និង លោកុត្តរសីល ។

ប្រការ ៣ តិកសីល ៥ តិកៈ

១. **ហីនមជ្ឈិមប្បណីតវសេន** ដោយហីនសីល មជ្ឈិមសីល និងបណីតសីល ។

២.**អត្តាធិបតេយ្យលោកាធិបតេយ្យធម្មាធិបតេយ្យវសេន** ដោយអត្តាធិបតេយ្យសីល លោកាធិបតេយ្យសីល និង ធម្មាធិប-តេយ្យសីល ។

៣. **បរាមដ្ឋាបរាមដ្ឋប្បដិប្បស្សទ្ធិវសេន** ដោយបរាមដ្ឋសីល អបរាមដ្ឋសីល និង បដិប្បស្សទ្ធិសីល ។

៤. **វិសុទ្ធាវិសុទ្ធវេមតិកវសេន** ដោយវិសុទ្ធសីល អវិសុទ្ធ-សីល និង វេមតិកសីល ។

៥. **សេខាសេខនេវសេខានាសេខវសេន** ដោយសេក្ខសីល អសេក្ខសីល និង នេវសេក្ខានាសេក្ខសីល ។

ប្រភេទ ៤ ចតុក្កសីល ៤ ចតុក្កៈ

១. ហានភាគិយឋិតិភាគិយវិសេសភាគិយនិព្វេធភាគិយ-វសេន ដោយហានភាគិយសីល ឋិតិភាគិយសីល វិសេស-ភាគិយសីល និង និព្វេធភាគិយសីល ។

២. ភិក្ខុភិក្ខុនីអនុបសម្បន្នគហដ្ឋសីលវសេន ដោយ ភិក្ខុសីល ភិក្ខុនីសីល អនុបសម្បន្នសីល និង គហដ្ឋសីល ។

៣. បកតិអាចារធម្មតាបុព្វហេតុកសីលវសេន ដោយ បកតិសីល អាចារសីល ធម្មតាសីល និង បុព្វហេតុកសីល ។

៤. បាតិមោក្ខសំវរឥន្ទ្រិយសំវរអាជីវបារិសុទ្ធិបច្ចយ-សន្និស្សិតសីលវសេន ដោយបាតិមោក្ខសំវរសីល ឥន្ទ្រិយ-សំវរសីល អាជីវបារិសុទ្ធិសីល និង បច្ចយសន្និស្សិតសីល ។

ប្រភេទ ៥ បញ្ចកសីល ២ បញ្ចកៈ

១. បរិយន្តបារិសុទ្ធិអបរិយន្តបារិសុទ្ធិបរិបុណ្ណបារិសុទ្ធិ-អបរាមដ្ឋបារិសុទ្ធិបដិប្បស្សទ្ធិបារិសុទ្ធិសីលវសេន ដោយ បរិយន្តបារិសុទ្ធិសីល អបរិយន្តបារិសុទ្ធិសីល បរិបុណ្ណបារិសុទ្ធិ-សីល អបរាមដ្ឋបារិសុទ្ធិសីល និង បដិប្បស្សទ្ធិបារិសុទ្ធិសីល ។

២.បហានវេរមណីចេតនាសំវរាវីតិក្កមវសេន ដោយបហាន សីល វេរមណីសីល ចេតនាសីល សំវរសីល និងអវីតិក្កមសីល ។

* អធិប្បាយចតុប្បារិសុទ្ធិសីល *

* យំ ភគវតា ឥជ ភិក្ខុ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសូតិ ឯវំ វុត្តំ សីលមិទំ បាតិមោក្ខសំវរសីលំ នាម ។ សីលណាដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រព្រឹត្តសង្រួម ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ ដោយអាចារៈ និងគោចរៈ មានប្រក្រតីឃើញទោសមានប្រមាណ តិចតួចថាជាភ័យធំ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ សីលនេះឈ្មោះថា បាតិមោក្ខសំវរសីល ។

*យំ បន សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំ-វុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃាយិត្វា ។បេ។ ជីវ្ហាយ រសំ សាយិត្វា ។បេ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ប។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ ។បេ។ មនិន្ទ្រិយេ

សំវរំ អាបជ្ជតីតិ វុត្តំ ឥទំ ឥន្ទ្រិយសំវរសីលំ ឆាម ។ សីលណាដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះ ឃើញរូបដោយចក្ខុ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ឯអកុសលធម៌ទាំងឡាយដ៏លាមក គឺ អភិជ្ឈា និងទោមនស្ស តែងគ្រប់សង្កត់នូវបុគ្គលនុ៎ះ ដែលមិនបានសង្រួមនូវចក្ខុន្ទ្រិយ៍ ព្រោះហេតុមិនសង្រួម នូវចក្ខុន្ទ្រិយ៍ណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយ៍នោះ រមែងរក្សានូវចក្ខុន្ទ្រិយ៍ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ៍ ។ល។ ឮសម្លេងដោយត្រចៀក ។ល។ ធុំក្លិនដោយច្រមុះ ។ល។ ដឹងរសដោយអណ្តាត ។ល។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ល។ ដឹងធម្មារម្មណ៍ដោយចិត្ត មិនកាន់យកនូវនិមិត្ត ។ល។ ដល់នូវការសង្រួមក្នុងចិត្ត សីលនេះឈ្មោះថាឥន្ទ្រិយសំវរសីល ។

* យា បន អាជីវហេតុ អាជីវការណា បញ្ញត្តានំ ឆន្នំ សិក្ខាបទានំ វីតិក្កមស្ស កុហនា លបនា នេមិត្តិកតា និប្បេសិកតា លាភេន លាភំ និជិគីសនតាតិ ឯវមាទីនញ្ច បាបធម្មានំ វសេន បវត្តា មិច្ឆាជីវា វិរតិ ឥទំ អាជីវបារិសុទ្ធិសីលំ ។ ការវៀរចាកមិច្ឆាជីវៈ ដែលប្រព្រឹត្តទៅដោយអំណាច នៃការប្រព្រឹត្តកន្លងសិក្ខាបទទាំងឡាយ ៦ ដែលព្រះមានព្រះភាគបញ្ញត្តហើយ ព្រោះមានអាជីវៈជាហេតុ

មានអាជីវៈ ជាដំណើរ និងដែលប្រព្រឹត្តទៅដោយអំណាចនៃបាបធម៌ទាំងឡាយយ៉ាងនេះ គឺ **កុហនា លបនា នេមិត្តិកតា និប្បេសិកតា លាភេន លាភំ និជិគីសនតា** ជាដើម សីលនេះឈ្មោះថា អាជីវបារិសុទ្ធិសីល ។

* **បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយាតិ អាទិនា នយេន វុត្តោ បដិសង្ខានបរិសុទ្ធោ ចតុប្បច្ចយបរិភោគោ ឥទំ បច្ចយសន្និស្សិតសីលំ នាម** ។ ការបរិភោគបច្ច័យ ៤ បរិសុទ្ធបានដោយការពិចារណាតាមន័យដែលព្រះសាស្ដាត្រាស់ថា **បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយ** ដូច្នេះជាដើម សីលនេះឈ្មោះថា បច្ចយសន្និស្សិតសីល ។

សិក្ខាបទ ៦ ទាក់ទងនឹងអាជីវៈ

១. **អាជីវហេតុ អាជីវការណា បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ អាបត្តិ បារាជិកស្ស** ។ ព្រោះអាជីពជាហេតុ ព្រោះអាជីពជាដំណើរ ភិក្ខុមានសេចក្ដីប្រាថ្នាអាក្រក់ ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ ពោលអួតឧត្តរិមនុស្សធម៌ដែលមិនមានពិត ត្រូវអាបត្តិបារាជិក ។

២. អាជីវហេតុ អាជីវការណា សញ្ចរិត្តំ សមាបជ្ជតិ អាបត្តិ សង្ឃាទិសេសស្ស ។ ព្រោះអាជីពជាហេតុ ព្រោះអាជីពជាដំណើរ ភិក្ខុប្រព្រឹត្តដឹកនាំដំណឹងបុរសស្ត្រីដល់គ្នានឹងគ្នា ត្រូវអាបត្តិសង្ឃាទិសេស ។

៣. អាជីវហេតុ អាជីវការណា យោ តេ វិហារេ វសតិ សោ ភិក្ខុ អរហាតិ ភណតិ បដិជានន្តស្ស អាបត្តិ ថុល្លច្ចយស្ស ។ ព្រោះអាជីពជាហេតុ ព្រោះអាជីពជាដំណើរ ភិក្ខុពោលថា ភិក្ខុរូបណានៅក្នុងវិហាររបស់អ្នក ភិក្ខុរូបនោះជាព្រះអរហន្ត កាលគេដឹងច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ ។

៤. អាជីវហេតុ អាជីវការណា ភិក្ខុ បណីតភោជនានិ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ចាចិត្តិយស្ស ។ ព្រោះអាជីពជាហេតុ ព្រោះអាជីពជាដំណើរ ភិក្ខុមិនមានជំងឺ សូមបណីតភោជន ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយៈ ។

៥. អាជីវហេតុ អាជីវការណា ភិក្ខុនី បណីតភោជនានិ អគិលានា អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ចាដិទេសនីយស្ស ។ ព្រោះអាជីពជាហេតុ ព្រោះអាជីព

ជាដំណើរ ភិក្ខុនីមិនមានជំងឺ សូមបណីតភោជន ដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់ ត្រូវអាបត្តិបាដិទេសនីយៈ ។

៦. អាជីវហេតុ អាជីវការណា សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ ព្រោះអាជីពជាហេតុ ព្រោះអាជីពជាដំណើរ ភិក្ខុមិនមានជំងឺ សូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់ត្រូវអាបត្តិទុក្កដ ។

និទ្ទេសនៃបាបធម៌ ៥

តត្ថ កតមា កុហនា ។ បណ្តាបាបធម៌ ៥ នោះ កុហនាតើដូចម្តេច ?

លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆា-បកតស្ស យា បច្ចយប្បដិសេវនសង្ខាតេន វា សាមន្ត-ជប្បិតេន វា ឥរិយាបថស្ស វា អដ្ឋបនា ឋបនា សណ្ឋបនា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ អយំ វុច្ចតិ កុហនា ។ ការប្រុងប្រៀបខាងដើម អាការប្រុងប្រៀប ការរៀបចំឥរិយាបថ ការធ្វើមុខស្រពោន ការមានមុខស្រពោន ការកុហក ការប្រព្រឹត្ត

ទៅនៃការកុហក ភាពជាអ្នកឆបោក ដោយការសេពនូវបច្ច័យក្ដី ដោយការខ្សឹបខ្សៀវក្ដី របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និង ការសរសើរ មានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នា គ្របសង្កត់ហើយ នេះហៅថា **កុហនា** ។

តត្ថ កតមា លបនា ។ បណ្ដាបាបធម៌ ៥ នោះ **លបនា** តើដូចម្ដេច ?

លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆា-បកតស្ស យា បរេសំ អាលបនា លបនា សល្លបនា ឧល្លបនា សមុល្លបនា ឧន្នហនា សមុន្នហនា ឧក្កាបនា សមុក្កាបនា អនុប្បិយភាណិតា ចាដុកម្យតា មុគ្គសូបតា បារិភដ្យតា អយំ វុច្ចតិ លបនា ។ ការរាក់ទាក់រក ការនិយាយរាក់ទាក់ ចំពោះពួកជនដទៃ ការ និយាយល្បួង ការនិយាយលើកតម្កើង ការនិយាយបញ្ចោរ ការនិយាយចងចិត្តត្រកូល ការបញ្ចើច ការបញ្ចើចបញ្ចោរត្រកូល ការបញ្ចើចបញ្ចោររឿយៗ ការនិយាយចាក់បណ្ដោយ ការប្រព្រឹត្ត បន្ទន់កាយ ភាពជាអ្នកមានវាចាដូចសម្លសណ្ដែកបាយ ការបី ពទារកនៃត្រកូលណា របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និង ការសរសើរ មានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាគ្រប សង្កត់ហើយ នេះហៅថា **លបនា** ។

តត្ថ កតមា នេមិត្តិកតា ។ បណ្ដាបាបធម៌ ៥ នោះ **នេមិត្តិកតា** តើដូចម្ដេច ?

លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស យំ បរេសំ និមិត្តំ និមិត្តកម្មំ ឱភាសោ ឱភាសកម្មំ សាមន្តជប្បា បរិកថា អយំ វុច្ចតិ នេមិត្តិកតា ។ និមិត្ត ការធ្វើនូវនិមិត្ត ការនិយាយបំភ្លឺ ការធ្វើនូវការបំភ្លឺ ការពោលបញ្ឆិតបញ្ឆៀង ការនិយាយកោសរូសណា ចំពោះពួកជនដទៃ របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងការសរសើរ មានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា **នេមិត្តិកតា** ។

តត្ថ កតមា និប្បេសិកតា ។ បណ្ដាបាបធម៌ ៥ នោះ **និប្បេសិកតា** តើដូចម្ដេច ?

លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស យា បរេសំ អក្កោសនា វម្ភនា គរហនា ឧក្ខេបនា សមុក្ខេបនា ខិបនា សង្ខិបនា បាបនា សម្បាបនា អវណ្ណហារិកា បរបិដ្ឋិមំសិកតា អយំ វុច្ចតិ និប្បេសិកតា ។ ការជេរប្រទេច ការបន្តុះបង្អាប់ ការតិះដៀល ការនិយាយយាត់ ការនិយាយយាត់រឿយៗ ការនិយាយចំអក ការនិយាយ

ចំអករឿយៗ ចំពោះជនដទៃ ការញុំាងទាយកឱ្យដល់នូវទោស ការញុំាងទាយកឱ្យដល់នូវទោសរឿយៗ ការដើរនិយាយទោសអ្នកដទៃ ភាពជាអ្នកមានវាចាល្អតែក្នុងទីចំពោះមុខ របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និង ការសរសើរ មានសេចក្តីប្រាថ្នាលាមកត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា **និប្បេសិកតា** ។

តត្ថ កតមា លាភេន លាភំ និជិគីសនតា ។ បណ្តាបាបធម៌ ៥ នោះ **លាភេន លាភំ និជិគីសនតា** តើដូចម្តេច ? **លាភសក្ការសិលោកសន្និស្សិតោ បាបិច្ឆោ ឥច្ឆាបកតោ ឥតោ លទ្ធំ អាមិសំ អមុត្រ ហរតិ អមុត្រ វា លទ្ធំ អាមិសំ ឥធាហរតិ យា ឯវរូបា អាមិសេន អាមិសស្ស ឯដ្ឋិ គវេដ្ឋិ បរិយេដ្ឋិ ឯសនា គវេសនា បរិយេសនា អយំ វុច្ចតិ លាភេន លាភំ និជិគីសនតា ។** ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងការសរសើរ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នាំយកអាមិសដែលខ្លួនបានហើយ អំពីផ្ទះឯណេះ ទៅឱ្យផ្ទះឯណោះ ឬនាំយកអាមិសដែលខ្លួនបានហើយ អំពីផ្ទះឯណោះ មកឱ្យផ្ទះឯណេះ ការប្រាថ្នា ការស្វែងរក ការស្វែងរករឿយៗ ការគន់រក ការរំពៃរក ការស្វែងរកញឹកញាប់នូវអាមិសដោយអាមិស មានសភាពដូច្នេះ នេះហៅថា **លាភេន លាភំ និជិគីសនតា** ។

សាធនៈ ៤ និង សុទ្ធិ ៤ យ៉ាង

១. **បាតិមោក្ខសំវរសីល** ជាសទ្ធាសាធនៈ និងជាទេសនាសុទ្ធិ

២. **ឥន្ទ្រិយសំវរសីល** ជាសតិសាធនៈ និងជាសំវរសុទ្ធិ

៣. **អាជីវបារិសុទ្ធិសីល** ជាវីរិយសាធនៈ និងជាបរិយេដ្ឋិសុទ្ធិ

៤. **បច្ចយសន្និស្សិតសីល** ជាបញ្ញាសាធនៈនិងជាបច្ចវេក្ខណសុទ្ធិ

ការបរិភោគមាន ៤ យ៉ាង

១. ថេយ្យបរិភោគោ ការបរិភោគដូចជាអ្នកលួច បានដល់ការបរិភោគរបស់ភិក្ខុទ្រុស្តសីលទាំងឡាយ ។

២. ឥណបរិភោគោ ការបរិភោគដូចជាអ្នកជាប់បំណុល បានដល់ ការបរិភោគរបស់ភិក្ខុមានសីលតែមិនបានពិចារណា ។

៣. ទាយជ្ជបរិភោគោ ការបរិភោគដូចជាអ្នកទទួលមរតក បានដល់ ការបរិភោគរបស់ព្រះសេក្ខបុគ្គលទាំងឡាយ ។

៤. សាមិបរិភោគោ ការបរិភោគដូចជនជាម្ចាស់ទ្រព្យ បានដល់ការបរិភោគរបស់ព្រះខីណាស្រពទាំងឡាយ ។

* បច្ចយសន្និស្សិតសីល *

សូម្បីបច្ចយសន្និស្សិតសីល រមែងសម្រេចបាន ដោយការពិចារ-ណា ព្រោះហេតុនោះ ភិក្ខុគួរពិចារណាហើយសឹមបរិភោគនូវ

បច្ច័យទាំងឡាយ ។ ក៏ការពិចារណានោះមាន ២ ដំណាក់កាល គឺ

១. **បដិលាភកាល** (កាលបានបច្ច័យ)

២. **បរិភោគកាល** (កាលបរិភោគ)

បណ្ដាកាលទាំង ២ នោះ ក្នុងកាលទទួល ភិក្ខុគួរពិចារណាឱ្យឃើញថាជាធាតុ ឬឱ្យឃើញថាជារបស់បដិកូលគួរខ្ពើម (ធាតុប្បច្ចវេក្ខណៈ ឬបដិកូលបច្ចវេក្ខណៈ) ។ ចំណែកក្នុងកាលបរិភោគគួរពិចារណាតាមន័យដែលព្រះសាស្ដាត្រាស់ថា **បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ** ដូច្នេះជាដើម ។

ចីវរប្បច្ច័យ

ក្នុងចីវរបច្ច័យកំណត់ដែនរបស់ប្រយោជន៍មាន ៤ គឺ ៖

១. **សីតស្ស បដិឃាតាយ** ដើម្បីការពារនូវត្រជាក់,

២. **ឧណ្ហស្ស បដិឃាតាយ** ដើម្បីការពារនូវកម្ដៅ,

៣. **ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ** ដើម្បីការពារនូវសម្ផស្សនៃសត្វរបោម សត្វមូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូចធំទាំងឡាយ,

៤. **ហិរិកោបិនប្បដិច្ឆាទនត្ថំ** ដើម្បីបិទបាំងនូវអវយវៈដែលធ្វើសេចក្ដីខ្មាសឱ្យកម្រើក ។

បិណ្ឌបាតប្បច្ច័យ

ក្នុងបិណ្ឌបាតបច្ច័យចាត់ជាអង្គដែលត្រូវហាមឃាត់មាន ៤ និងដែនរបស់ប្រយោជន៍មាន ៨ រួមជា ១២ គឺ ៖

១. **នេវ ទវាយ** មិនមែនដើម្បីលេងដូចក្មេងអ្នកស្រុក,

២. **ន មទាយ** មិនមែនឱ្យកើតបុរិសមានៈស្រវឹងដូចអ្នកប្រដាល់,

៣. **ន មណ្ឌនាយ** មិនមែនដើម្បីប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរី,

៤. **ន វិភូសនាយ** មិនមែនដើម្បីស្អិតស្អាងរាងកាយធ្វើឱ្យផូរផង់ពណ៌សម្បុរដូចអ្នកលេងរបាំ (ទាំង ៤ នេះជាអង្គត្រូវហាមឃាត់)

១. **ឥមស្ស កាយស្ស ឋិតិយា** ដើម្បីការតាំងនៅនៃកាយនេះ,

២. **យាបនាយ** ដើម្បីញុំាងជីវិតិន្ទ្រិយ៍ឱ្យប្រព្រឹត្តទៅ,

៣. **វិហឹសុបរតិយា** ដើម្បីបំបាត់បង់នូវសេចក្តីលំបាក,

៤. **ព្រហ្មចរិយានុគ្គហាយ** ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌,

៨. **ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ** អាត្មាអញ នឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង,

៦. **នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** អញនឹងមិនញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណឱ្យកើតឡើងបានផង,

៧. **យាត្រា ច មេ ភវិស្សតិ** កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ នឹងមានដល់អាត្មាអញផង,

៨. **អនវជ្ជតា ច** សេចក្តីមិនមានទោស មានមិនច្រអូសកាយនិងចិត្តជាដើមនឹងមានដល់អាត្មាអញ (ព្រោះការបរិភោគនេះ) ផង។

* ចំណែក **ផាសុវិហារោ ច** (ការនៅសប្បាយផង) ចាត់ជាអានិសង្សដូច្នេះឯង ។

សេនាសនប្បច្ច័យ

ក្នុងសេនាសនបច្ច័យ កំណត់ដែនរបស់ប្រយោជន៍មាន ៥ គឺ ៖

១. **សីតស្ស បដិឃាតាយ** ដើម្បីការពារនូវត្រជាក់,

២. **ឧណ្ហស្ស បដិឃាតាយ** ដើម្បីការពារនូវកម្តៅ,

៣. **ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ** ដើម្បីការពារនូវសម្ផស្សនៃសត្វរបោម សត្វមូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចធំទាំងឡាយ,

៤. **ឧតុបរិស្សយវិនោទនំ** ដើម្បីបន្ទោបង់នូវគ្រោះចង្រៃក្រវល់ក្រវាយដែលកើតអំពីរដូវ,

៥. **បដិសល្លានារាមត្ថំ** ដើម្បីអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

គិលានប្បច្ច័យ

ចំណែកក្នុងគិលានបច្ច័យដែនរបស់ប្រយោជន៍មាន ១ ប៉ុណ្ណោះ គឺ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយ ដើម្បីការពារនូវវេទនាទាំងឡាយដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

* ភិក្ខុអ្នកមានប្រាជ្ញា គួរសិក្សាឱ្យស្គាល់ខេត្តដែននៃប្រយោជន៍ក្នុងការប្រើប្រាស់បច្ច័យមានប្រការដូច្នេះឯង ។

ឆ្លើយសំនួរទី ៦ , ៧ ថា

៦. ខណ្ឌាទិភាវោ សីលស្ស សង្កិលេសោ ។ ភាវៈនៃទោសមានការដាច់ជាដើមជាសេចក្តីសៅហ្មងរបស់សីល ។

៧. អខណ្ឌាទិភាវោ វោទានំ ។ ការមិនដាច់ជាដើម ជាសេចក្តីផូរផង់របស់សីល ។

សោ បន ខណ្ឌាទិភាវោ លាភយសាទិហេតុកេន ភេទេន ច សត្តវិធមេថុនសំយោគេន ច សង្គហិតោ ។ ក៏ភាវៈនៃសេចក្តីសៅហ្មងមានការដាច់ជាដើមនោះលោកសង្គ្រោះយកហើយដោយការបែកធ្លាយ ព្រោះលាភ យស ជាដើមជាហេតុផង ដោយមេថុនសំយោគ ៧ ប្រការផង ។

ធុតង្គនិទ្ទេស

ភគវតា ហិ បរិច្ចត្តលោកាមិសានំ កាយេ ច ជីវិតេ ច អនបេក្ខានំ អនុលោមប្បដិបទំយេវ អារាធេតុកាមានំ កុលបុត្តានំ តេរស ធុតង្គានិ អនុញ្ញាតានិ ។
ធុតង្គទាំង ១៣ ព្រះមានព្រះភាគអនុញ្ញាតហើយ ដល់កុលបុត្រទាំងឡាយ អ្នកមានលោកាមិសៈលះបង់ហើយ មិនអាល័យក្នុងកាយ និងជីវិត មានប្រាថ្នាដើម្បីញ៉ាំងអនុលោមប្បដិបទាឱ្យសម្រេចតែម្យ៉ាង ។

មាតិកាធុតង្គទាំង ១៣

១. **បំសុកូលិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយាទ្រទ្រង់សំពត់បំសុកូលជាប្រក្រតី ។

២. **តេចីវរិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយាទ្រទ្រង់ចីវរ ៣ ពោលគឺសង្ឃាដិ ឧត្តរាសង្គៈ និង អន្តរវាសកៈ ជាប្រក្រតី ។

៣. **បិណ្ឌបាតិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាវត្ត ។

៤. **សបទានចារិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះជាប្រក្រតី ។

៥. **ឯកាសនិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយាឆាន់លើអាសនៈតែមួយជាប្រក្រតី ។

៦. **បត្តបិណ្ឌិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយាឆាន់ក្នុងបាត្រតែមួយជាប្រក្រតី ។

៧. **ខលុបច្ឆាភត្តិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយាហាមភត្តហើយមិនទទួលឆាន់អតិរិត្តភោជនខាងក្រោយទៀត ជាប្រក្រតី ។

៨. **អារញ្ញិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅក្នុងព្រៃ ជាប្រក្រតី ។

៩. **រុក្ខមូលិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅទៀបគល់ឈើជាប្រក្រតី ។

១០. **អព្ភោកាសិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅក្នុងទីវាលជាប្រក្រតី ។

១១. **សោសានិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅក្នុងទីស្មសានជាប្រក្រតី ។

១២. **យថាសន្ថតិកង្គំ** អង្គរបស់ភិក្ខុអ្នកមានកិរិយានៅក្នុងទីសេនាសនៈតាមដែលគេចាត់ឱ្យជាប្រក្រតី ។

១៣. **នេសជ្ជិកង្គំ** អង្គរបស់ភិក្ខុអ្នកហាមការដេកហើយនៅដោយការអង្គុយ ជាប្រក្រតី ។

លក្ខណៈនៃធុតង្គ

តត្ថ អត្ថតោ លក្ខណាទីហិ សមាទានវិធានតោ
បភេទតោ ភេទតោ ច តស្ស តស្សានិសំសតោ
កុសលត្តិកតោ ចេវ ធុតាទីនំ វិភាគតោ
សមាសព្យាសតោ ចាបិ វិញ្ញាតព្វោ វិនិច្ឆយោ ។

ព្រះយោគាវចរទាំងឡាយ គប្បីសិក្សាឱ្យស្គាល់លក្ខណៈវិនិច្ឆ័យធុតង្គទាំង ១៣ នោះ ដោយអត្ថ ១ ដោយលក្ខណាទិចតុក្កៈ ១ ដោយវិធីសមាទាន និងវិធីប្រតិបត្តិ ១ ដោយប្រភេទ ១ ដោយការបែកធ្លាយ ១ ដោយអានិសង្សនៃធុតង្គនោះៗ ១ ដោយកុសលត្តិកៈ ១ ដោយការចែកស័ព្ទមានធុតស័ព្ទជាដើម ១ ដោយសង្ខេប និងពិស្តារ ១ ។

វិនិច្ឆ័យដោយអត្ថ

១. បំសុ វិយ កុច្ឆិតភាវំ ឧលតីតិ បំសុកូលំ ។ កុច្ឆិតភាវំ គច្ឆតីតិ វុត្តំ ហោតិ ។ សំពត់ដែលបានឈ្មោះថា បំសុកូល ព្រោះអត្ថថា ទៅកាន់ភាពជារបស់គួរខ្ពើមដូចធូលី អធិប្បាយថា ដល់នូវភាពគួរខ្ពើម ។ បំសុកូលស្ស ធារណំ បំសុកូលំ ។ ការទ្រទ្រង់នូវសំពត់ដែលដល់នូវភាពគួរខ្ពើមដូចធូលី ឈ្មោះថា បំសុកូល ។ បំសុកូលំ សីលមស្សាតិ បំសុកូលិកោ ។ ការទ្រទ្រង់នូវសំពត់បំសុកូលជាប្រក្រតីរបស់ភិក្ខុនោះ ព្រោះហេតុ

នោះ លោកទើបឈ្មោះថា បំសុកូលិកភិក្ខុ ។ **បំសុកូលិកស្ស អង្គំ បំសុកូលិកង្គំ** ។ អង្គនៃភិក្ខុអ្នកមានកិរិយាទ្រទ្រង់នូវសំពត់បំសុកូលជាប្រក្រតី ឈ្មោះថា បំសុកូលិកង្គៈ ។ **អង្គន្តិ ការណំ វុច្ចតិ ។ តស្មា យេន សមាទានេន សោ បំសុកូលិកោ ហោតិ តស្សេតំ អធិវចនន្តិ វេទិតព្វំ ។** ហេតុ លោកហៅថា អង្គ ព្រោះហេតុនោះ ភិក្ខុនោះ ជាអ្នកបានឈ្មោះថា បំសុកូលិកភិក្ខុ ដោយការសមាទានណា ពាក្យថា អង្គ នេះ គប្បីជ្រាបថា ជាឈ្មោះនៃការសមាទាននោះឯង ។

២. **សង្ឃាដិឧត្តរាសង្គអន្តរវាសកសង្ខាតំ តិចីវរំ សីលមស្សាតិ តេចីវរិកោ ។ តេចីវរិកស្ស អង្គំ តេចីវរិកង្គំ ។** ភិក្ខុអ្នកមានកិរិយាទ្រទ្រង់ត្រៃចីវរ ជាប្រក្រតី ។ អង្គនៃភិក្ខុអ្នកមានកិរិយាទ្រទ្រង់ត្រៃចីវរជាប្រក្រតី ឈ្មោះថា តេចីវរិកង្គៈ ។

៣. **បិណ្ឌាយ បតិតុំ វត្តមេតស្សាតិ បិណ្ឌបាតី ។ បិណ្ឌបាតី ឯវ បិណ្ឌបាតិកោ ។ បិណ្ឌបាតិកស្ស អង្គំ បិណ្ឌបាតិកង្គំ** ។ ភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាវត្ត ។ អង្គនៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាវត្ត ឈ្មោះថា បិណ្ឌបាតិកង្គៈ ។

៤. សបទានំ ចរិតុំ ឥទមស្ស សីលន្តិ សបទានចារី ។ តស្ស អង្គំ សបទានចារិកង្គំ ។ ភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះជាប្រក្រតី ។ អង្គនៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះ ជាប្រក្រតីនោះ ឈ្មោះថា សបទានចារិកង្គៈ ។

៥. ឯកាសនេ ភោជនំ ឯកាសនំ, តំ សីលមស្សាតិ ឯកាសនិកោ ។ តស្ស អង្គំ ឯកាសនិកង្គំ ។ ការឆាន់លើអាសនៈតែមួយៗ នោះជាប្រក្រតី របស់ភិក្ខុនោះ ហេតុនោះ លោកទើបឈ្មោះថា ឯកាសនិកភិក្ខុ ។ អង្គនៃឯកាសនិកភិក្ខុនោះ ឈ្មោះថា ឯកាសនិកង្គៈ ។

៦. បត្តបិណ្ឌសញ្ញំ កត្វា បត្តបិណ្ឌោ សីលមស្សាតិ បត្តបិណ្ឌិកោ ។ តស្ស អង្គំ បត្តបិណ្ឌិកង្គំ ។ ភិក្ខុអ្នកមានដុំបាយក្នុងបាត្រតែមួយជាប្រក្រតី (ឆាន់ក្នុងបាត្រមួយជាប្រក្រតី) ។ អង្គនៃភិក្ខុអ្នកមានដុំបាយក្នុងបាត្រតែមួយ ជាប្រក្រតីនោះ ឈ្មោះថា បត្តបិណ្ឌិកង្គៈ ។

៧. បច្ឆាភត្តំ សីលមស្សាតិ បច្ឆាភត្តិកោ, ន បច្ឆាភត្តិកោ ខលុបច្ឆាភត្តិកោ ។ តស្ស អង្គំ ខលុបច្ឆាភត្តិកង្គំ ។ ភិក្ខុអ្នកមានកិរិយាមិនឆាន់ភត្តខាងក្រោយទៀត ជាប្រក្រតី ។

អង្គនៃភិក្ខុអ្នកមានកិរិយាមិនឆាន់ភត្តខាងក្រោយទៀត ជាប្រក្រតីនោះ ឈ្មោះថា ខលុបច្ឆាភត្តិកង្គៈ ។

៨. អរញ្ញេ និវាសោ អរញ្ញំ, តំ សីលមស្សាតិ អារញ្ញិកោ ។ តស្ស អង្គំ អារញ្ញិកង្គំ ។ ការនៅក្នុងព្រៃ១ នោះជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ លោកទើបឈ្មោះថា អារញ្ញិកភិក្ខុ ។ អង្គនៃអារញ្ញិកភិក្ខុនោះ ឈ្មោះថា អារញ្ញិកង្គៈ ។

៩. រុក្ខមូលេ និវាសោ រុក្ខមូលំ, តំ សីលមស្សាតិ រុក្ខមូលិកោ ។ តស្ស អង្គំ រុក្ខមូលិកង្គំ ។ ការនៅក្រោមដើមឈើ១ នោះជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ លោកទើបឈ្មោះថា រុក្ខមូលិកភិក្ខុ ។ អង្គនៃរុក្ខមូលិកភិក្ខុនោះ ឈ្មោះថា រុក្ខមូលិកង្គៈ ។

១០. អព្ភោកាសេ និវាសោ អព្ភោកាសោ, អព្ភោកាសោ សីលមស្សាតិ អព្ភោកាសិកោ ។ តស្ស អង្គំ អព្ភោកាសិកង្គំ ។ ការនៅក្នុងទីវាល១ នោះជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ លោកទើបឈ្មោះថា អព្ភោកាសិកភិក្ខុ ។ អង្គនៃអព្ភោកាសិកភិក្ខុនោះ ឈ្មោះថា អព្ភោកាសិកង្គៈ ។

១១. សោសានេ និវាសោ សោសានំ, តំ សីលមស្សាតិ សោសានិកោ ។ តស្ស អង្គំ សោសានិកង្គំ ។

ការនៅក្នុងទីស្មសានៗ នោះជាប្រក្រតីរបស់ភិក្ខុនោះ ហេតុនោះ លោកទើបឈ្មោះថាសោសានិកភិក្ខុ ។ អង្គនៃសោសានិកភិក្ខុនោះ ឈ្មោះថា សោសានិកង្គៈ ។

១២. តស្មឹ យថាសន្ថតេ វិហរិតុំ សីលមស្សាតិ យថាសន្ថតិកោ ។ តស្ស អង្គំ យថាសន្ថតិកង្គំ ។ ភិក្ខុអ្នកមានកិរិយានៅ ក្នុងទីសេនាសនៈ តាមដែលគេចាត់ឱ្យជាប្រក្រតី ។ អង្គនៃភិក្ខុអ្នកមានកិរិយានៅក្នុងទីសេនាសនៈ តាមដែលគេចាត់ឱ្យជាប្រក្រតីនោះ ឈ្មោះថា យថាសន្ថតិកង្គៈ ។

១៣. សយនំ បដិក្ខិបិត្វា និសជ្ជាយ វិហរិតុំ សីលមស្សាតិ នេសជ្ជិកោ ។ តស្ស អង្គំ នេសជ្ជិកង្គំ ។ ភិក្ខុអ្នកហាមការដេក ហើយនៅដោយការអង្គុយជាប្រក្រតី ។ អង្គនៃភិក្ខុអ្នកហាមការដេក ហើយនៅដោយការអង្គុយជាប្រក្រតីនោះ ឈ្មោះថា នេសជ្ជិកង្គៈ ។

វិនិច្ឆ័យដោយលក្ខណាទិចតុក្កៈ

១. **សមាទានចេតនាលក្ខណានិ** ធុតង្គទាំងអស់នោះ មានសមាទានចេតនាជាលក្ខណៈ ,

២. **លោលុប្បវិទ្ធំសនរសានិ** មានកិរិយាកម្ចាត់នូវសេចក្ដីល្មោភជាកិច្ច ,

៣. **និល្លោលុប្បការបច្ចុបដ្ឋានាជិ** មិនមានសេចក្តីល្មោភជាអាការប្រាកដ ,

៤. **អប្បិច្ឆតាជិអរិយធម្មបធដ្ឋានាជិ** មានអរិយធម៌ គឺសេចក្តីប្រាថ្នាតិចជាដើម ជាហេតុជិត ។

វិនិច្ឆ័យដោយការសមាទាន

១. ជាដំបូង គប្បីសមាទានក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធ

២. ព្រះអសីតិមហាសាវ័ក

៣. ព្រះអរិយបុគ្គលទាំងឡាយ មានព្រះខីណាស្រពជាដើម

៤. ភិក្ខុអ្នកទ្រទ្រង់ព្រះត្រៃបិដក, ភិក្ខុទ្រទ្រង់និកាយមួយជាដើម

៥. អដ្ឋកថាចារ្យ, អ្នកទ្រទ្រង់ធុតង្គ ។

៦. បើមិនមានបុគ្គលប្រាកដដូច្នោះ គប្បីបោសសំអាតទីលាននៃព្រះចេតិយ៍ ហើយអង្គុយច្រហោងផ្គងអញ្ជលីពោលសមាទានហាក់ដូចជាពោលក្នុងសម្នាក់នៃព្រះសម្មាសម្ពុទ្ធដូច្នោះ ។ **អបិច សយម្បិ សមាទាតុំ វដ្ដតិ ឯវ** ។ម្យ៉ាងទៀត សូម្បីសមាទានខ្លួនឯង ក៏គួរដូចគ្នា ។

១. វិធីសមាទានបំសុកូលិកធុតង្គ

១. **គហបតិទានចីវរំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមចីវរដែលគហបតីប្រគេន ។

២. បំសុក្កូលិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយាទ្រទ្រង់សំពត់បំសុកូល ជាប្រក្រតី ។

២. វិធីសមាទានតេចីវរិកធុតង្គ

១. ចតុត្ថចីវរំ បដិក្ខិបាមិ ខ្ញុំព្រះករុណា សូមហាមនូវចីវរទី ៤

២. តេចីវរិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយាទ្រទ្រង់ចីវរ ៣ ជាប្រក្រតី ។

៣. វិធីសមាទានបិណ្ឌបាតិកធុតង្គ

១. អតិរេកលាភំ បដិក្ខិបាមិ ខ្ញុំព្រះករុណា សូមហាមអតិរេកលាភ ។

២. បិណ្ឌបាតិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាវត្ត ។

៤. វិធីសមាទានសបទានចារិកធុតង្គ

១. លោលុប្បចារំ បដិក្ខិបាមិ ខ្ញុំព្រះករុណា សូមហាមការត្រាច់ទៅបិណ្ឌបាតដោយសេចក្ដីលោភ ។

២. សបទានចារិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះជាប្រក្រតី ។

៥. វិធីសមាទានឯកាសនិកធុតង្គ

១. នានាសនភោជនំ បដិក្ខិចាមិ ខ្ញុំព្រះករុណា សូមហាមការឆាន់លើអាសនៈផ្សេងៗ ។

២. ឯកាសនិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គ នៃភិក្ខុអ្នកមានកិរិយាឆាន់លើអាសនៈមួយ ជាប្រក្រតី ។

៦. វិធីសមាទានបត្តបិណ្ឌិកធុតង្គ

១. ទុតិយភាជនំ បដិក្ខិចាមិ ខ្ញុំព្រះករុណា សូមហាមភាជន៍ជាគម្រប់ពីរ ។

២. បត្តបិណ្ឌិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយាឆាន់ក្នុងបាត្រមួយជាប្រក្រតី ។

៧. វិធីសមាទានខលុបច្ឆាភត្តិកធុតង្គ

១. អតិរិត្តភោជនំ បដិក្ខិចាមិ ខ្ញុំព្រះករុណា សូមហាមនូវអតិរិត្តភោជន ។

២. ខលុបច្ឆាភត្តិកង្គំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកហាមភត្តហើយ មិនឆាន់អតិរិត្តភោជនខាងក្រោយទៀត ជាប្រក្រតី ។

៨. វិធីសមាទានអារញ្ញិកធុតង្គ

១. **គាមន្តសេនាសនំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមសេនាសនៈក្នុងស្រុក ។

២. **អារញ្ញិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយានៅក្នុងព្រៃជាប្រក្រតី ។

៩. វិធីសមាទានរុក្ខមូលិកធុតង្គ

១. **ឆន្នំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមនូវទីប្រក់ ។

២. **រុក្ខមូលិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយានៅទៀបគល់ឈើជាប្រក្រតី ។

១០. វិធីសមាទានអព្ភោកាសិកធុតង្គ

១. **ឆន្នញ្ច រុក្ខមូលញ្ច បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមទីប្រក់ និងរុក្ខមូល ។

២. **អព្ភោកាសិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយានៅក្នុងទីវាលជាប្រក្រតី ។

១១. វិធីសមាទានសោសានិកធុតង្គ

១. **ន សុសានំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមទីដែលមិនមែនជាទីស្មសាន ។

២. **សោសានិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយានៅក្នុងទីស្មសាន ជាប្រក្រតី ។

១២. វិធីសមាទានយថាសន្ថតិកធុតង្គ

១. **សេនាសនលោលុប្បំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមសេចក្ដីលោភក្នុងសេនាសនៈ ។

២. **យថាសន្ថតិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកមានកិរិយានៅ ក្នុងទីសេនាសនៈ តាមដែលគេចាត់ឱ្យជាប្រក្រតី ។

១៣. វិធីសមាទាននេសជ្ជិកធុតង្គ

១. **សេយ្យំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមឥរិយាបថដេក

២. **នេសជ្ជិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទានអង្គនៃភិក្ខុអ្នកហាមការដេក ហើយនៅដោយការអង្គុយ ជាប្រក្រតី ។

* **ឥមេសុ ទ្វីសុ វចនេសុ អញ្ញតរេន សមាទិន្នំ ហោតិ ។** បណ្ដាពាក្យសមាទានទាំងពីរយ៉ាងនេះ ព្រះយោគាវចរសមាទានដោយពាក្យណាមួយក៏បាន ។

វិនិច្ឆ័យដោយប្រភេទ

ធុតង្គទាំងអស់នោះ ពោលដោយប្រភេទមាន ៣ ប្រភេទដូចគ្នា គឺ

១. **ឧក្កដ្ឋោ** ប្រភេទឧក្រិដ្ឋ, (ប្រព្រឹត្តិតឹងតែង)

២. **មជ្ឈិមោ** ប្រភេទមជ្ឈិម, (ប្រព្រឹត្តិជាកណ្តាល)

៣. **មុទុ** ប្រភេទមុទុ, (ប្រព្រឹត្តិធូរថយ) ។

វិនិច្ឆ័យដោយការបែកធ្លាយ

១. តេសុ យស្ស កស្សចិ អត្តនោ រុចិយា ខន្តិយា គិហីហិ ទិន្នកាំ សាទិតក្ខណេ ធុតង្គំ ភិជ្ជតិ ។ បណ្តាបំសុកូលិកភិក្ខុទាំង ៣ ប្រភេទនោះ ធុតង្គរបស់ភិក្ខុរូបណាមួយ រមែងបែកធ្លាយ ក្នុងខណៈដែលត្រេកអរនឹងចីវរដែលគ្រហស្ថទាំងឡាយ ប្រគេនតាមសេចក្តីពេញចិត្តរបស់ខ្លួន ។

២. ឥមេសំ បន តិណ្ណម្បិ ចតុត្ថកចីវរំ សាទិតក្ខណេយេវ ធុតង្គំ ភិជ្ជតិ ។ ចំណែកធុតង្គរបស់តេចីវរិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយក្នុងខណៈដែលត្រេកអរនឹងចីវរជាគម្រប់ ៤ ។

៣. ឥមេសំ បន តិណ្ណម្បិ សង្ឃភត្តាទិអតិរេកលាភំ សាទិតក្ខណេយេវ ធុតង្គំ ភិជ្ជតិ ។ ធុតង្គរបស់បិណ្ឌបាតិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយក្នុងខណៈដែលត្រេកអរនឹងអតិរេកលាភ មានសង្ឃភត្តជាដើម ។

៤. ឥមេសំ បន តិណ្ណម្បិ លោលុប្បចារេ ឧប្បន្នមត្តេ ធុតង្គំ ភិជ្ជតិ ។ ធុតង្គរបស់សបទានចារិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយ ក្នុងកាលលោកត្រាច់ទៅបិណ្ឌបាត ដោយសេចក្តីលោភ ។

៥. ឥមេសំ បន តិណ្ណម្បិ នានាសនភោជនំ ភុត្តក្ខណេ ធុតង្គំ ភិជ្ជតិ ។ ធុតង្គរបស់ឯកាសនិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយ ក្នុងកាលលោកអង្គុយឆាន់លើអាសនៈផ្សេងៗ ។

៦. ឥមេសំ បន តិណ្ណម្បិ ទុតិយភាជនំ សាទិតក្ខណេ ធុតង្គំ ភិជ្ជតិ ។ ឯធុតង្គរបស់បត្តបិណ្ឌិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយ ក្នុងខណៈដែលត្រេកអរនឹងភាជន៍ ជាគម្រប់ពីរ ។

៧. ឥមេសំ បន តិណ្ណម្បិ បវារិតានំ កប្បិយំ ការេត្វា ភុត្តក្ខណេ ធុតង្គំ ភិជ្ជតិ ។ ធុតង្គរបស់ខលុបច្ឆាភត្តិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយក្នុងកាលដែលខ្លួនហាមភត្តហើយ ប្រើគេឱ្យធ្វើវិនយកម្មហើយឆាន់ ។

៨. ឥមេសំ បន តិណ្ណម្បិ អត្តនោ វា រុចិយា គាមន្តសេនា-សនេ អរុណំ ឧដ្ឋាបេន្តានំ ធុតង្គំ ភិជ្ជតិ ។ ធុតង្គរបស់អារញ្ញិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយ ក្នុងកាលលោកបិតនៅ

ក្នុងស្រុកតាមសេចក្ដីពេញចិត្តរបស់ខ្លួនដរាបដល់អរុណរះឡើង ។
៩. ឥមេសំ បន តិណ្ណម្បិ ឆន្នេ វាសំ កប្បិតក្ខណេ ធុតង្គំ ភិជ្ជតិ ។ ធុតង្គរបស់រុក្ខមូលិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយ ក្នុងខណៈដែលលោកសម្រេចការនៅក្នុងទីដែលគេប្រក់ ។
១០. ឥមេសំ បន តិណ្ណម្បិ វាសត្ថាយ ឆន្នញ្ច រុក្ខមូលញ្ច បវិដ្ឋក្ខណេ ធុតង្គំ ភិជ្ជតិ ។ ចំណែកធុតង្គរបស់អព្ភោកាសិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយក្នុងខណៈដែលលោកចូលទៅកាន់ទីប្រក់ក្ដី រុក្ខមូលក្ដី ដើម្បីប្រយោជន៍ដល់ការនៅ ។
១១. ឥមេសំ បន តិណ្ណម្បិ ន សុសានម្ហិ វាសកប្បនេន ធុតង្គំ ភិជ្ជតិ ។ ឯធុតង្គរបស់សោសានិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយព្រោះសម្រេចការនៅក្នុងទីមិនមែនជាទីស្មសាន ។
១២. ឥមេសំ បន តិណ្ណម្បិ សេនាសនលោលុប្បេ ឧប្បន្នមត្តេ ធុតង្គំ ភិជ្ជតិ ។ ឯធុតង្គរបស់យថាសន្ថតិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយក្នុងខណៈត្រឹមតែសេចក្ដីលោភក្នុងសេនាសនៈ កើតឡើង ។
១៣. ឥមេសំ បន តិណ្ណម្បិ សេយ្យំ កប្បិតមត្តេ ធុតង្គំ ភិជ្ជតិ ។ ធុតង្គរបស់នេសជ្ជិកភិក្ខុទាំង ៣ ប្រភេទនេះ រមែងបែកធ្លាយ ក្នុងខណៈត្រឹមតែលោកសម្រេចការដេកប៉ុណ្ណោះ ។

ទិនិច្ឆ័យដោយអានិសង្ស

ភិក្ខុអ្នកទ្រទ្រង់ធុតង្គ រមែងបាននូវគុណដ៏ប្រសើរ ៩ យ៉ាង ជាដើមគឺ ៖

១. អប្បិច្ឆតា ការប្រាថ្នាតិច

២. សន្តុដ្ឋិតា សេចក្ដីសន្ដោស

៣. សល្លេខតា ការប្រព្រឹត្តជុសខាត់កិលេស

៤. បវិវេកតា សេចក្ដីស្ងប់ស្ងាត់

៥. អបចយតា ការមិនសន្សំកិលេស

៦. វីរិយារម្ភតា ការប្រារព្ធសេចក្ដីព្យាយាម

៧. សុភរតា ភាពជាអ្នកដែលគេចិញ្ចឹមងាយ

៨. អប្បកិច្ចតា ភាពជាអ្នកមានការងារតិច

៩. សល្លហុកតា ភាពជាអ្នកមានកាយនិងចិត្តស្រាលជាដើម ។

ទិនិច្ឆ័យដោយកុសលត្តិកៈ

សព្វានេវ ហិ ធុតង្គានិ សេខបុថុជ្ជនក្ខីណាសវានំ វសេន សិយា កុសលានិ, សិយា អព្យាកតានិ, នត្ថិ ធុតង្គំ អកុសលន្តិ ។ ក៏ធុតង្គទាំងអស់ ជាកុសលក៏មាន

ជាអព្យាក្រឹតក៏មាន ដោយអំណាចនៃសេក្ខបុគ្គល បុថុជ្ជននិង ព្រះខីណាស្រពទាំងឡាយ ឯធុតង្គជាអកុសល មិនមានឡើយ ។

ការចែកសព្ទមានធុតសព្ទជាដើម

គប្បីជ្រាប ធុតៈ ធុតវាទ ធុតធម៌ ធុតង្គៈ និងការសេពធុតង្គ ជាសប្បាយដល់បុគ្គលណា ។

តត្ថ ធុតោតិ ធុតក្កិលេសោ វា បុគ្គលោ, កិលេស-ធុននោ វា ធម្មោ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា ធុតៈ បានដល់ បុគ្គលអ្នកមានកិលេសកម្ចាត់បង់ហើយ ឬធម៌ជាគ្រឿងកម្ចាត់បង់នូវកិលេស ។

ធុតវាទោតិ ឯត្ថ បន អត្ថិ ធុតោ ន ធុតវាទោ, អត្ថិ ន ធុតោ ធុតវាទោ, អត្ថិ នេវ ធុតោ ន ធុតវាទោ, អត្ថិ ធុតោ ចេវ ធុតវាទោ ច ។ ក្នុងពាក្យថា ធុតវាទនោះ បុគ្គលជាធុតៈ តែមិនមែនជាធុតវាទក៏មាន, បុគ្គលមិនមែនជាធុតៈ តែជាធុតវាទក៏មាន, បុគ្គលមិនមែនជាធុតៈផង មិនមែនជាធុតវាទផងក៏មាន, បុគ្គលជាធុតៈផង ជាធុតវាទផងក៏មាន ។

ធុតធម្មា វេទិតព្វាតិ អប្បិច្ឆតា សន្តុដ្ឋិតា សល្លេខតា បវិវេកតា ឥទមត្ថិតាតិ ឥមេ ធុតង្គចេតនាយ បរិវារកា បញ្ច ធម្មា អប្បិច្ឆំយេវ និស្សាយាតិ អាទិវចនតោ

ធុតធម្មា នាម ។ ធម៌ទាំងឡាយ ៥ នេះជាបរិវារនៃធុតង្គចេតនា គឺ **អប្បិច្ឆតា សន្តុដ្ឋិតា សល្លេខតា បវិវេកតា ឥទមត្ថិតា** ឈ្មោះថាធុតធម៌ ព្រោះព្រះបាលីថា ភិក្ខុជាអ្នកនៅព្រៃ ព្រោះអាស្រ័យសេចក្ដីប្រាថ្នាតិច ដូច្នេះជាដើម ។

ធុតង្គានិ វេទិតព្វានីតិ តេរស ធុតង្គានិ វេទិតព្វានិ បំសុកូលិកង្គំ ។បេ។ នេសជ្ជិកង្គន្តិ ។ ត្រង់ពាក្យថា គប្បីជ្រាប ធុតង្គទាំងឡាយ សេចក្ដីថា គប្បីជ្រាបធុតង្គទាំង ១៣ គឺ បំសុកូលិកង្គធុតង្គ ១ ។បេ។ នេសជ្ជិកង្គធុតង្គ ១ ។

កស្ស ធុតង្គសេវនា សប្បាយាតិ រាគចរិតស្ស ចេវ មោហចរិតស្ស ច, កស្មា, ធុតង្គសេវនា ហិ ទុក្ខាបដិបទា ចេវ សល្លេខវិហារោ ច ។ ត្រង់ពាក្យថា ការសេពធុតង្គជាសប្បាយដល់បុគ្គលណា ឆ្លើយថា ជាសប្បាយដល់បុគ្គលជារាគចរិត និងមោហចរិត ។ បើមានអ្នកសួរថា ព្រោះហេតុអ្វី ? គប្បីឆ្លើយថា ព្រោះការសេពធុតង្គជាទុក្ខាបដិបទាផង ជាសល្លេខវិហារធម៌ផង ។

វិនិច្ឆ័យដោយសង្ខេបនិងដោយពិស្ដារ

សមាសព្យាសតោតិ ឥមានិ បន ធុតង្គានិ សមាសតោ តីណិ សីសង្គានិ បញ្ច អសម្ភិន្នង្គានីតិ អដ្ឋេវ ហោន្តិ ។

ក៏ធុតង្គទាំងឡាយនេះ ដោយបំប្រួញមាន ៨ ប៉ុណ្ណោះ គឺ អង្គដែលជាប្រធានមាន ៣ អង្គដែលមិនលាយគ្នាមាន ៥ ។ **បុន ទ្វេ ចីវរប្បដិសំយុត្តានិ, បញ្ច បិណ្ឌបាតប្បដិសំយុត្តានិ, បញ្ច សេនាសនប្បដិសំយុត្តានិ, ឯកំ វីរិយប្បដិសំយុត្តន្តិ ឯវំ ចត្តារោ វ ហោន្តិ** ។ ដោយសង្ខេបមួយយ៉ាងទៀតធុតង្គទាំងអស់មាន ៤ ប៉ុណ្ណោះ គឺទាក់ទងនឹងចីវរមាន ២, ទាក់ទងនឹងបិណ្ឌបាតមាន ៥, ទាក់ទងនឹងសេនាសនៈមាន ៥, ទាក់ទងនឹងវីរិយៈមាន ១ ។ **បុន សព្វានេវ និស្សយវសេន ទ្វេ ហោន្តិ បច្ចយនិស្សិតានិ ទ្វាទស, វីរិយនិស្សិតំ ឯកន្តិ ។ សេវិតព្វាសេវិតព្វវសេនាបិ ទ្វេយេវ ហោន្តិ** ។ មួយទៀតធុតង្គទាំងអស់ដោយសង្ខេបមាន ២ យ៉ាង ដោយអំណាយនៃទីអាស្រ័យ គឺធុតង្គដែលអាស្រ័យបច្ច័យមាន ១២ ដែលអាស្រ័យវីរិយៈមាន ១ ។ និងមាន ២ យ៉ាង ដោយអំណាចធុតង្គគួរសេពនិងមិនគួរសេព ។

សព្វានេវ ចេតនាវសេន ឯកវិធានិ ហោន្តិ ឯកាយេវ ហិ ធុតង្គសមាទានចេតនាតិ អដ្ឋកថាសុបិ វុត្តំ ។ (ន័យម្យ៉ាងទៀត) ធុតង្គទាំងអស់ មានតែមួយយ៉ាង ដោយអំណាចនៃចេតនា, សមដូចពាក្យដែលលោកពោលទុក ក្នុងអដ្ឋកថា

ទាំងឡាយថា **ឯកាយេវ ហិ ធុតង្គសមាទានចេតនា**, ក៏ធុតង្គទាំង ១៣ មានតែម្យ៉ាងប៉ុណ្ណោះ គឺចេតនាក្នុងការសមាទាននូវធុតង្គ ។ ព្យាសតោ បន ភិក្ខូនំ តេរស, ភិក្ខុនីនំ អដ្ឋ, សាមណេរានំ ទ្វាទស, សិក្ខមានាសាមណេរីនំ សត្ត, ឧបាសកឧបាសិកានំ ទ្វេតិ ទ្វេចត្តាឡីស ធុតង្គានិ ហោន្តិ ។ ក៏ឯធុតង្គទាំងឡាយ (នោះ) ដោយពិស្តារមាន ៤២ គឺ ធុតង្គ ១៣ គួរដល់ភិក្ខុ, ធុតង្គ ៨ គួរដល់ភិក្ខុនី, ធុតង្គ ១២ គួរដល់សាមណេរ, ធុតង្គ ៧ គួរដល់សិក្ខមានានិងសាមណេរី, ធុតង្គ ២ គួរដល់ឧបាសក និងឧបាសិកាទាំងឡាយ ។

ចប់ មាតិកាធុតង្គ ។

១. អានិសង្សនៃបំសុកូលិកង្គធុតង្គ

១. បំសុកូលចីវរំ និស្សាយ បព្វជ្ជាតិ វចនតោ និស្សយា-នុរូបប្បដិបត្តិសព្ភាវោ សម្រេចការបដិបត្តិដ៏សមគួរដល់និស្ស័យតាមព្រះបាលីថា បព្វជិតត្រូវអាស្រ័យបំសុកូលចីវរ ដូច្នេះ ។

២. បឋមេ អរិយវំសេ បតិដ្ឋានំ តាំងនៅក្នុងអរិយវង្សទី ១ ។

៣. អារក្ខទុក្ខាភាវោ មិនលំបាកព្រោះការរក្សា ។

៤. **អបាយត្តវុត្តិតា** មានការប្រព្រឹត្តមិនជាប់ទាក់ទង នឹងបុគ្គលដទៃ ។

៥. **ចោរភយេន អភយតា** មិនមានភ័យព្រោះចោរភ័យ ។

៦. **បរិភោគតណ្ហាយ អភាវោ** មិនមានតណ្ហាក្នុងការប្រើប្រាស់ ។

៧. **សមណសារុប្បបរិក្ខារតា** មានបរិក្ខារដែលសមគួរដល់សមណភេទ ។

៨. **អប្បានិ ចេវ សុលភានិ ច តានិ ច អនវជ្ជានីតិ ភគវតា សំវណ្ណិតប្បច្ចយតា** មានបច្ច័យដែលព្រះមានព្រះភាគទ្រង់សរសើរហើយថា បំសុកូលចីវរ ជារបស់តិចផង រកបានងាយផង ទាំងសំពត់ទាំងឡាយនោះ ជារបស់មិនមានទោសផង ។

៩. **បាសាទិកតា** ជាបុគ្គលគួរឱ្យជ្រះថ្លា ។

១០. **អប្បិច្ឆតាទីនំ ផលនិប្ផត្តិ** សម្រេចនូវផលនៃគុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

១១. **សម្មាបដិបត្តិយា អនុព្រូហនំ** បង្កើននូវសម្មាបដិបត្តិរឿយៗ ។

១៤. បច្ឆិមាយ ជនតាយ ទិដ្ឋានុគតិអាចាជនំ បានជាទិដ្ឋានុគតិដល់ប្រជុំជនខាងក្រោយៗ ។

គាថាសម្ដែងអានិសង្សនៃបំសុកូលិកង្គធុតង្គ

មារសេនំ វិឃាតាយ បំសុកូលធរោ យតិ
សន្នទ្ធកវចោ យុទ្ធេ ខត្តិយោ វិយ សោភតិ
បហាយ កាសិកាទីនិ វរវត្ថានិ ធារិតំ
យំ លោកគរុនា កោ តំ បំសុកូលំ ន ធារយេ
តស្មា ហិ អត្តនោ ភិក្ខុ បដិញ្ញំ សមនុស្សរំ
យោគាវចរានុកូលម្ហិ បំសុកូលេ រតោ សិយាតិ ។

ភិក្ខុអ្នកទ្រទ្រង់សំពត់បំសុកូល រមែងល្អក្នុងកិរិយាកម្ចាត់នូវសេនានៃមារ ដូចខត្តិយរាជមានគ្រឿងក្រោះចងរួចហើយ កាលល្អក្នុងទីចំបាំង នរណាមិនគប្បីទ្រទ្រង់សំពត់បំសុកូលដែលព្រះលោកនាថទ្រង់លះចោលនូវសំពត់ដ៏ប្រសើរ មានសំពត់កើតក្នុងដែនកាសីជាដើមហើយទ្រទ្រង់នោះ ព្រោះហេតុនោះ ភិក្ខុកាលរលឹកឃើញនូវពាក្យប្ដេជ្ញារបស់ខ្លួន គប្បីជាអ្នកត្រេកអរក្នុងសំពត់បំសុកូលដែលជាឧបការៈដល់ការប្រព្រឹត្តព្យាយាមចុះ ។

២. អានិសង្សនៃតេចីវរិកង្គធុតង្គ

១. តេចីវរិកោ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន ភិក្ខុអ្នកទ្រទ្រង់ចីវរតែ ៣ ឈ្មោះថាជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សានូវកាយ ។

២. តេនស្ស បក្ខិនោ វិយ សមាទាយេវ គមនំ ការសមាទាន ហើយត្រាច់ទៅដោយចីវរ ៣ របស់ភិក្ខុនោះ ដូចគ្នានឹងការហើរទៅ របស់សត្វបក្សី ។

៣. អប្បសមារម្ភតា មានការប្រោះព្រួតិច ។

៤. វត្ថសន្និធិបរិវជ្ជនំ វៀរការសន្សំសំពត់ទុក ។

៥. សល្លហុកវុត្តិតា ភាពជាអ្នកមានការប្រព្រឹត្តស្រាល ។

៦. អតិរេកលោលុប្បហានំ លះបង់សេចក្ដីលោភលន់ហួស ប្រមាណ ។

៧. កប្បិយេ មត្តការិតា ធ្វើសេចក្ដីដឹងប្រមាណក្នុងរបស់គួរ,

៨. សល្លេខវុត្តិតា ជាអ្នកមានការប្រព្រឹត្តដុសខាត់កិលេស ។

៩. អប្បិច្ឆតាទីនំ ផលនិប្ផត្តិ សម្រេចផលនៃគុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

* គុណទាំងឡាយមានយ៉ាងនេះជាដើម រមែងសម្រេច ដល់លោក ។

គាថាសម្តែងអានិសង្សនៃតេចីវរិកធុតង្គ

អតិរេកវត្ថតណ្ហំ បហាយ សន្និធិវិវជ្ជិតោ ធីរោ
សន្តោសសុខរសញ្ញូ តិចីវរធរោ ភវតិ យោគី
តស្មា សបត្តចរណោ បក្ខីវ សចីវរោ វ យោគិវរោ
សុខមនុវិចរិតុកាមោ ចីវរនិយមេ រតឹ កយិរា ។

ភិក្ខុអ្នកមានប្រាជ្ញា វៀរចាកការសន្សំ (នូវចីវរ) លះបង់សេចក្តីជាប់ចំពាក់ ក្នុងចីវរច្រើនហើយ រមែងដឹងនូវរសនៃសេចក្តីសុខដែលកើតពីការសន្តោស ភិក្ខុអ្នកមានព្យាយាមគួរជាអ្នកទ្រទ្រង់ចីវរ ៣ ព្រោះហេតុនោះ ភិក្ខុអ្នកមានព្យាយាមដ៏ប្រសើរ កាលប្រាថ្នាដើម្បីត្រាច់ទៅជាសុខ ជាអ្នកមានតែចីវរប៉ុណ្ណោះ (ត្រាច់ទៅ) ដូចសត្វបក្សីមានតែស្លាបហើយទៅ, គប្បីធ្វើសេចក្តីរីករាយ ក្នុងការកំណត់ក្នុងចីវរចុះ ។

៣. អានិសង្សនៃបិណ្ឌបាតិកង្គធុតង្គ

១. បិណ្ឌិយាលោបភោជនំ និស្សាយ បព្វជ្ជាតិ វចនតោ និស្សយានុរូបប្បដិបត្តិសព្ភាវោ កើតការបដិបត្តិដ៏សមគួរដល់និស្ស័យ តាមព្រះបាលីថា បព្វជិតត្រូវអាស្រ័យនូវភោជនដុំពំនូតដូច្នេះ ។

២. **ទុតិយេ អរិយវំសេ បតិដ្ឋានំ** តាំងនៅក្នុងអរិយវង្សទី ២ ។

៣. **អបរាយត្តវុត្តិតា** មានការប្រព្រឹត្តមិនជាប់ទាក់ទងដោយបុគ្គលដទៃ ។

៤. **អប្បានិ ចេវ សុលភានិ ច តានិ ច អនវជ្ជានីតិ ភគវតា សំវណ្ណិតប្បច្ចយតា** មានបច្ច័យដែលព្រះមានព្រះ-ភាគទ្រង់សរសើរហើយថា ជារបស់តិចផង រកបានងាយផង ទាំងវត្ថុទាំងនោះ មិនមានទោសផង ។

៥. **កោសជ្ជនិម្មថនតា** ញ៉ាំញីនូវសេចក្តីខ្ជិលច្រអូសបាន ។

៦. **បរិសុទ្ធាជីវិតា** មានជីវិតដ៏បរិសុទ្ធ ។

៦. **សេខិយប្បដិបត្តិបូរណំ** ញ៉ាំងសេខិយបដិបត្តិឱ្យបរិបូណ៌ ។

៧. **អបរចោសិតា** មិនប្រព្រឹត្តចិញ្ចឹមនូវបុគ្គលដទៃ ។

៨. **បរានុគ្គហកិរិយា** ធ្វើសេចក្តីសង្គ្រោះដល់បុគ្គលដទៃ ។

៩. **មានប្បហានំ** លះបង់មានះចេញបាន ។

១០. **រសតណ្ហានិវារណំ** ហាមឃាត់នូវចំណង់ក្នុងរស ។

១១. **គណភោជនបរម្បរភោជនចារិត្តសិក្ខាបទេហិ អនាបត្តិ** មិនត្រូវអាបត្តិព្រោះគណភោជនសិក្ខាបទ បរម្បរភោជនសិក្ខាបទ និងចារិត្តសិក្ខាបទ ។

១២. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា មានការប្រព្រឹត្តដែលអនុលោមដល់គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

១៣. សម្មាបដិបត្តិព្រូហនំ សម្មាបដិបត្តិចម្រើនឡើង ។

១៤. បច្ឆិមាជនតានុកម្បនំ អនុគ្រោះដល់បច្ឆាជនទាំងឡាយ ។

គាថាសម្តែងអានិសង្សនៃបិណ្ឌបាតិកធុតង្គ

បិណ្ឌិយាលោបសន្តុដ្ឋោ អបរាយត្តជីវកោ

បហីនាហារលោលុប្បោ ហោតិ ចាតុទ្ទិសោ យតិ

វិនោទយតិ កោសជ្ជំ អាជីវស្ស វិសុជ្ឈតិ

តស្មា ហិ នាតិមញ្ញេយ្យ ភិក្ខាចារំ សុមេធសោ ។

ភិក្ខុអ្នកមានព្យាយាម ជាអ្នកសន្តោសដោយដុំបាយជាពុំនូត មានការចិញ្ចឹមជីវិតមិនជាប់ដោយបុគ្គលដទៃ ជាអ្នកមានសេចក្តីលោភក្នុងអាហារលះបង់ហើយ មានទិសទាំង ៤ ជាទីគោចរ បន្ទោបង់សេចក្តីខ្ជិលចេញ មានជីវិតដ៏បរិសុទ្ធ ព្រោះហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញាល្អ មិនគប្បីមើលងាយការត្រាច់ទៅដើម្បីភិក្ខាឡើយ ។

៤. អានិសង្សនៃសបទានចារិកធុតង្គ

១. កុលេសុ និច្ចនវកតា ជាបុគ្គលថ្មីជានិច្ចក្នុងត្រកូលទាំងឡាយ ។

២. **ចន្ទូបមតា** ជាបុគ្គលប្រៀបដូចនឹងព្រះចន្ទ ។

៣. **កុលមច្ឆេរប្បហានំ** លះសេចក្តីកំណាញ់ក្នុងត្រកូលចេញបាន ។

៤. **សមានុកម្បិតា** ជាអ្នកមានការអនុគ្រោះស្មើ ។

៥. **កុលុបកាជីវភាវោ** មិនមានទោស ព្រោះការចូលទៅកាន់ត្រកូល ។

៦. **អភ្ជានភិនន្ទនា** មិនមានសេចក្តីត្រេកអរនឹងការហៅរក ។

៧. **អភិហារេ អនត្ថិកតា** មិនមានសេចក្តីត្រូវការដោយភិក្ខាដែលគេនាំមកចំពោះខ្លួន ។

៨. **អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** មានការប្រព្រឹត្តដែលអនុលោមដល់គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

គាថាសម្តែងអានិសង្សនៃសបទានចារិកធុតង្គ

ចន្ទូបមោ និច្ចនវោ កុលេសុ អមច្ឆរី សព្វសមានុកម្បោ កុលូបកាជីវវិប្បមុត្តោ ហោតីធ ភិក្ខុ សបទានចារី លោលុប្បចារំ បជហាយ តស្មា ឱក្ខិត្តចក្ខុ យុគមត្តទស្សី អាកង្ខមានោ ភុវិ សេរិចារំ ចរេយ្យ ធីរោ សបទានចារំ ។

សបទានចារិកភិក្ខុ ក្នុងសាសនានេះ លះបង់នូវការចូលទៅបិណ្ឌបាតទាំងសេចក្តីលោភជាអ្នកមានចន្ទ្រាជាគ្រឿងប្រៀបធៀប

ថ្មីជានិច្ចក្នុងត្រកូលទាំងឡាយ មិនមានសេចក្តីកំណាញ់ មានសេចក្តីអនុគ្រោះស្មើដល់ជនទាំងពួង ជាអ្នកផុតស្រឡះពីទោសក្នុងការចូលទៅកាន់ត្រកូល ព្រោះហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញាជាអ្នកមានចក្ខុដាក់ចុះហើយ សម្លឹងមើលត្រឹមមួយជួរនឹម កាលប្រាថ្នាយ៉ាងក្រៃលែងនូវការត្រាច់ទៅដោយសេរី គប្បីប្រព្រឹត្តនូវសបទាចារិកធុតង្គចុះ ។

៥. អានិសង្សនៃឯកាសនិកធុតង្គ

១. **អប្បាពាធតា** មានអាពាធតិច ។

២. **អប្បាតង្កតា** មិនមានសេចក្តីលំបាក ។

៣. **លហុដ្ឋានំ** ការក្រោកឡើងរហ័សរហួន ។

៤. **ពលំ** មានកម្លាំងកាយ ។

៥. **ផាសុវិហារោ** កិរិយានៅជាសុខ ។

៦. **អនតិរិត្តប្បច្ចយា អនាបត្តិ** មិនត្រូវអាបត្តិ ព្រោះឆាន់អនតិរិត្តភោជនជាបច្ច័យ ។

៧. **រសតណ្ហាវិនោទនំ** បន្ទោបង់រសតណ្ហាបាន ។

៨. **អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** មានការប្រព្រឹត្តដែលអនុលោមដល់គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

គាថាសម្តែងអានិសង្សនៃឯកាសនិកធុតង្គ

ឯកាសនភោជនេ រតំ ន យតឹ ភោជនប្បច្ចយា រុជា
វិសហន្តិ រសេ អលោលុប្បោ បរិហាបេតិ ន កម្មមត្តនោ
ឥតិ ផាសុវិហារការណោ សុចិសល្លេខរតូបសេវិតេ
ជនយេថ វិសុទ្ធមានសោ រតិមេកាសនភោជនេ យតិ ។

រោគទាំងឡាយ ដែលមានភោជនជាបច្ច័យ រមែងមិនបៀតបៀនភិក្ខុអ្នកត្រេកអរក្នុងការបរិភោគលើអាសនៈតែមួយ ភិក្ខុអ្នកមិនមានសេចក្តីល្មោភក្នុងរស រមែងមិនញ៉ាំងការងាររបស់ខ្លួនឱ្យសាបសូន្យឡើយ ព្រោះហេតុនោះ ព្រះយោគីអ្នកមានចិត្តបរិសុទ្ធគប្បីញ៉ាំងសេចក្តីត្រេកអរឱ្យកើតឡើងក្នុងការបរិភោគលើអាសនៈតែមួយ ជាហេតុនៃការនៅជាសុខ ដែលភិក្ខុអ្នកត្រេកអរក្នុងសល្លេខធម៌ដ៏ស្អាតចូលទៅសេពគប់ហើយ ។

៦. អានិសង្សនៃបត្តបិណ្ឌិកង្គ

១. នានារសតណ្ហាវិនោទនំ បន្ទោបង់នូវសេចក្តីជាប់ចិត្តក្នុងរសផ្សេងៗ ។

២. អត្រិច្ឆតាយ បហានំ លះបង់សេចក្តីលោភលន់ ។

៣. អាហារេ បយោជនមត្តទស្សិតា ជាអ្នកឃើញត្រឹមតែប្រយោជន៍ក្នុងអាហារ ។

៤. **ជាលិកាទិបរិហរណខេតាភាវោ** មិនមានសេចក្តីលំបាកក្នុងការរក្សានូវថាសជាដើម ។

៥. **អវិក្ខិត្តភោជិតា** ជាអ្នកមានចិត្តមិនរាយមាយហើយបរិភោគ

៦. **អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** មានការប្រព្រឹត្តដែលអនុលោមដល់គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

គាថាសម្តែងអានិសង្សនៃបត្តបិណ្ឌិកធុតង្គ

នានាភាជនវិក្ខេបំ ហិត្វា ឱក្ខិត្តលោចនោ
ខណោន្តោ វិយ មូលានិ រសតណ្ហាយ សុព្វតោ
សរូបំ វិយ សន្តុដ្ឋី ធារយន្តោ សុមានសោ
បរិភុញ្ជេយ្យ អាហារំ កោ អញ្ញោ បត្តបិណ្ឌិកោតិ ។

ភិក្ខុអ្នកមានវត្តល្អ ជាអ្នកមានភាពក្រឡេមក្រឡើមដាក់ចុះហើយលះបង់នូវការរាយមាយក្នុងភាជន៍ផ្សេងៗ ហាក់ដូចជាដកនូវឫសគល់នៃរសតណ្ហា ជាអ្នកមានចិត្តល្អ កាលទ្រទ្រង់នូវសេចក្តីសន្តោស ដូចជាទ្រទ្រង់រូបរបស់ខ្លួន បត្តបិណ្ឌិកភិក្ខុដទៃណាគប្បីបរិភោគនូវអាហារ (ប្រាកដដូច្នោះ) បាន ។

៧. អានិសង្សនៃខលុបច្ឆាភត្តិកធុតង្គ

១. **អនតិរិត្តភោជនាបត្តិយា ទូរីភាវោ** ជាអ្នកឆ្ងាយអំពីអាបត្តិដែលមានការបរិភោគអនតិរិត្តភោជន (ជាហេតុ) ។

២. **ឱទរិកត្តាភាវោ** ជាអ្នកមិនមានពោះតឹងណែន ។

៣. **និរាមិសសន្និធិតា** មិនមានការសន្សំនូវអាមិសៈទុក ។

៤. **បុន បរិយេសនាយ អភាវោ** មិនមានការស្វែងរកទៀត ។

៥. **អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** មានការប្រព្រឹត្តដែលអនុលោមដល់គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

គាថាសម្តែងអានិសង្សនៃខលុបច្ឆាភត្តិកធុតង្គ

បរិយេសនាយ ខេទំ ន យាតិ ន ករោតិ សន្និធឹ ធីរោ

ឱទរិកត្តំ បជហាតិ ខលុបច្ឆាភត្តិកោ យោគី

តស្មា សុគតប្បសត្ថំ សន្តោសគុណាទិវុឌ្ឍិសញ្ជននំ

ទោសេ វិធុនិតុកាមោ ភជេយ្យ យោគី ធុតង្គមិទន្តិ ។

ខលុបច្ឆាភត្តិកភិក្ខុមានប្រាជ្ញា រមែងមិនដល់នូវការលំបាក ព្រោះការស្វែងរក មិនធ្វើនូវការសន្សំ តែងលះបង់នូវភាពជាអ្នកមានពោះតឹងបាន ព្រោះហេតុនោះ ភិក្ខុអ្នកប្រកបព្យាយាម មានប្រាថ្នាដើម្បីកម្ចាត់នូវទោសទាំងឡាយ គប្បីសេពនូវធុតង្គនេះ ដែលព្រះសុគតសរសើរហើយ ដែលញ៉ាំងគុណមានសេចក្តីសន្តោសជាដើមឱ្យកើតឡើង ។

៨. អានិសង្សនៃអារញ្ញិកធុតង្គ

១. អារញ្ញិកោ ភិក្ខុ អរញ្ញសញ្ញំ មនសិករោន្តោ ភព្វោ អលទ្ធំ វា សមាធឹ បដិលទ្ធុំ លទ្ធំ វា រក្ខិតុំ អារញ្ញិកភិក្ខុ កាលធ្វើសេចក្តីសម្គាល់ថា ព្រៃ ព្រៃ ដូច្នេះទុកក្នុងចិត្ត គួរដើម្បីបាននូវសមាធិដែលខ្លួនមិនទាន់បាន ឬគួរដើម្បីរក្សានូវសមាធិដែលខ្លួនបានហើយ ។

២. សត្ថាបិស្ស អត្តមនោ ហោតិ ។ យថាហ តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោតិ អរញ្ញវិហារេនាតិ សូម្បីព្រះសាស្តា ក៏ទ្រង់មានហឫទ័យរីករាយចំពោះភិក្ខុនោះ ។ សមដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ទុកថា ម្នាលនាគិតៈ តថាគតមានចិត្តត្រេកអរនឹងភិក្ខុនោះ ព្រោះការនៅព្រៃ ។

៣. បន្តសេនាសនវាសិនោ ចស្ស អសប្បាយរូបាទយោ ចិត្តំ ន វិក្ខិបន្តិ អារម្មណ៍ទាំងឡាយមានរូបមិនជាទីសប្បាយជាដើម រមែងមិនរំខានចិត្តរបស់ភិក្ខុដែលជាអ្នកនៅ ក្នុងសេនាសនៈស្ងាត់នោះ ។

៤. វិគតសន្តាសោ ហោតិ ជាអ្នកមានសេចក្តីតក់ស្លុតទៅប្រាសហើយ ។

៥. ជីវិតនិកន្តឹ បជហាតិ លះបង់សេចក្តីពេញចិត្តក្នុងជីវិតចេញបាន ។

៦. បវិវេកសុខរសំ អស្សាទេតិ រមែងរីករាយនឹងរសនៃសេចក្ដីសុខដែលកើតពីវិវេក ។

៧. បំសុកូលិកាទិភាវោបិ ចស្ស បដិរូបោ ហោតិ សូម្បីភាពជាបំសុកូលិកៈ (អ្នកទ្រទ្រង់សំពត់បំសុកូល) ជាដើម ជាគុណដ៏សមគួរដល់ភិក្ខុនោះ ។

គាថាសម្ដែងអានិសង្សនៃអារញ្ញិកធុតង្គ

បវិវិត្តោ អសំសដ្ឋោ បន្តសេនាសនេ រតោ
អារាធយន្តោ នាថស្ស វនវាសេន មានសំ
ឯកោ អរញ្ញេ និវាសំ យំ សុខំ លភតេ យតិ
រសំ តស្ស ន វិន្ទន្តិ អបិ ទេវា សឥន្ទកា ។
បំសុកូលញ្ច ឯសោវ ការចំ វិយ ធារយំ
អរញ្ញសង្គាមគតោ អវសេសធុតាយុធោ
សមត្ថោ ន ចិរស្សេវ ជេតុំ មារំ សវាហនំ
តស្មា អរញ្ញវាសម្ហិ រតឹ កយិរាថ បណ្ឌិតោតិ ។

ភិក្ខុអ្នកស្ងប់ស្ងាត់ មិននៅច្រឡូកច្រឡំ (ដោយពួកគណៈ) ជាអ្នកត្រេកអរក្នុងសេនាសនៈដ៏ស្ងាត់ រមែងញ៉ាំងហឫទ័យរបស់ព្រះ-លោកនាថឱ្យត្រេកអរបាន លោកតែម្នាក់ឯង កាលនៅក្នុងព្រៃ

រមែងបាននូវសេចក្តីសុខណា ឯទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រមិនបាននូវរសនៃសេចក្តីសុខនោះទេ ។ ភិក្ខុនេះឯងកាលទ្រទ្រង់នូវសំពត់បំសុកូលដូចជាគ្រឿងការពារ ទៅកាន់សង្គ្រាមគឺព្រៃ មានធុតង្គដ៏សេសជាគ្រឿងច្បាំង មិនយូរឡើយអាចឈ្នះនូវមារព្រមទាំងវាហនៈបានពុំខាន ព្រោះហេតុនោះ ភិក្ខុជាបណ្ឌិត គប្បីធ្វើនូវសេចក្តីត្រេកអរក្នុងអរញ្ញវាសីចុះ ។

៩. អានិសង្សនៃរុក្ខមូលិកង្គធុតង្គ

១. **រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជាតិ វចនតោ និស្សយានុរូបប្បដិបត្តិសព្ភាវោ** កើតការប្រតិបត្តិដែលសមគួរដល់និស្ស័យ តាមព្រះពុទ្ធដីកាថា បព្វជិតត្រូវអាស្រ័យរុក្ខមូលជាសេនាសនៈដូច្នេះ ។

២. **អប្បានិ ចេវ សុលភានិ ច តានិ ច អនវជ្ជានីតិ ភគវតា សំវណ្ណិតប្បច្ចយតា** ភាពជាអ្នកមានបច្ច័យដែលព្រះមានព្រះភាគសរសើរហើយថា ជារបស់តិចផង រកបានងាយផង ទាំងរបស់អស់នោះមិនមានទោសផង ។

៣. **អភិណ្ហំ តរុបណ្ណវិការទស្សនេន អនិច្ចសញ្ញាសមុដ្ឋាបនតា** ញ៉ាំងអនិច្ចសញ្ញាឱ្យកើតឡើង ដោយការឃើញនូវការប្រែប្រួលនៃស្លឹកឈើលាស់ថ្មីរឿយៗ ។

៤. សេនាសនមច្ឆេរកោម្នារាមតំ អភាវោ មិនមានសេចក្ដីកំណាញ់ក្នុងសេនាសនៈនិងភាពរីករាយក្នុងការងារ ។
៥. ទេវតាហិ សហវាសិតា បាននៅរួមជាមួយនឹងពួកទេវតា។
៦. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា មានការប្រព្រឹត្តដែលសមគួរដល់គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

គាថាសម្ដែងអានិសង្សនៃរុក្ខមូលិកធុតង្គ

វណ្ណិតោ ពុទ្ធសេដ្ឋេន និស្សយោតិ ច ភាសិតោ
និវាសោ បវិវិត្តស្ស រុក្ខមូលសមោ កុតោ
អាវាសមច្ឆេរហរេ ទេវតាបរិបាលិតេ
បវិវិត្តេ វសន្តោ ហិ រុក្ខមូលម្ហិ សុព្វតោ
អភិរត្តានិ នីលានិ បណ្ឌូនិ បតិតានិ ច
បស្សន្តោ តរុបណ្ណានិ និច្ចសញ្ញំ បនូទតិ
តស្មា ហិ ពុទ្ធទាយជ្ជំ ភាវនាភិរតាលយំ
វិវិត្តំ នាតិមញ្ញេយ្យ រុក្ខមូលំ វិចក្ខណោតិ ។

ប្រទេសជាទីនៅរបស់ភិក្ខុអ្នកស្ងប់ស្ងាត់ ដែលព្រះពុទ្ធដ៏ប្រសើរទ្រង់សរសើរនិងសម្ដែងហើយថាជាទីអាស្រ័យ (នៃបព្វជិត) ដូច្នេះស្មើដោយរុក្ខមូល នឹងមានមកពីណា ភិក្ខុអ្នកមានវត្តល្អកាលនៅ

ក្រោមដើមឈើ ដែលជាទីស្ងាត់ អាចនាំសេចក្តីកំណាញ់ក្នុងអាវាសទៅបាន និងជាទីដែលពួកទេវតារក្សាហើយ កាលឃើញនូវស្លឹកឈើទុំផង ខៀវផង លឿងផង ដែលធ្លាក់ចុះហើយនិងស្លឹកលាស់ថ្មី រមែងបន្ទោបង់នូវសេចក្តីសម្គាល់ថា ទៀង ចេញបាន ព្រោះហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញាជាគ្រឿងពិចារណា មិនត្រូវមើលងាយរុក្ខមូលជាទីស្ងាត់ ដែលជាមរតកនៃព្រះពុទ្ធ និងជាទីអាស្រ័យលោកអ្នកត្រេកអរក្នុងភាវនាឡើយ ។

១០. អានិសង្សនៃអព្ភោកាសិកង្គធុតង្គ

១. **អាវាសបលិពោធុបច្ឆេទោ** កាត់សេចក្តីកង្វល់ក្នុងអាវាសបាន ។

២. **ថីនមិទ្ធប្បនូទនំ** បន្ទោបង់សេចក្តីងងុយងោកងក់ចេញបាន

៣. **មិគកា វិយ អសង្គចារិនោ អនិកេតា វិហរន្តិ ភិក្ខវោតិ បសំសាយ អនុរូបតា និសង្គតា ចាតុទ្ទិសតា** ជាអ្នកមិនជាប់ចិត្តនឹងទីកន្លែង ជាអ្នកមានទិសទាំងបួនជាលំនៅ សមគួរដល់ការសរសើរថា ភិក្ខុទាំងឡាយ មានប្រក្រតីត្រាច់ទៅមិនជាប់ចំពាក់ មិនមានសេចក្តីនឹកអាល័យ ដូចពួកម្រឹគក្នុងព្រៃ។

៤. **អប្បិច្ឆតាទីនំ អនុលោមវុត្តិតា** មានការប្រព្រឹត្តដែលអនុលោមដល់គុណទាំងឡាយ មានការប្រាថ្នាតិចជាដើម ។

គាថាសម្តែងអានិសង្សនៃអព្ភោកាសិកង្គធុតង្គ

អនគារិយភាវស្ស អនុរូបេ អទុល្លភេ
តារាមណិវិតាណម្ហិ ចន្ទទីបប្បភាសិតេ
អព្ភោកាសេ វសំ ភិក្ខុ មិគភូតេន ចេតសា
ថីនមិទ្ធំ វិនោទេត្វា ភាវនារាមតំ សិតោ
បវិវេករសស្សាទំ នចិរស្សេវ វិន្ទតិ
យស្មា តស្មា ហិ សប្បញ្ញោ អព្ភោកាសេ រតោ សិយាតិ ។

ភិក្ខុអ្នកមានចិត្តដូចម្រឹគ កាលនៅក្នុងអព្ភោកាស ជាទីដែលគេរកបានដោយមិនលំបាក សមគួរដល់ភាពជាអ្នកមិនមានផ្ទះ មានហ្វូងតារាដូចជាកែវមណីជាពិតាន មានពន្លឺព្រះចន្ទបំភ្លឺហើយ រមែងបន្ទោបង់ថីនមិទ្ធៈចេញបាន លោកអាស្រ័យនូវភាពជាអ្នកត្រេកអរក្នុងភាវនា មិនយូរឡើយ នឹងបាននូវសេចក្តីត្រេកអរនឹងរសនៃវិវេកពុំខាន ព្រោះហេតុនោះ ភិក្ខុអ្នកមានបញ្ញា គប្បីជាអ្នកត្រេកអរក្នុងអព្ភោកាសចុះ ។

១១. អានិសង្សនៃសោសានិកង្គធុតង្គ

១. មរណស្សតិប្បដិលាភោ បានមរណស្សតិ ។
២. អប្បមាទវិហារតា រស់នៅមិនប្រមាទ ។

៣. អសុភនិមិត្តានិគមោ សម្រេចបានអសុភនិមិត្ត ។

៤. កាមរាគវិនោទនំ បន្ទោបង់កាមរាគៈចេញបាន ។

៥. អភិណ្ហំ កាយសភាវទស្សនំ ឃើញសភាពនៃរូបកាយរឿយៗ ។

៦. សំវេគពហុលតា ជាអ្នកច្រើនដោយសេចក្តីសង្វេគ ។

៧. អារោគ្យមទានិប្បហានំ លះបង់សេចក្តីស្រវឹង មានការស្រវឹងព្រោះមិនមានរោគជាដើមចេញបាន ។

៨. ភយភេរវសហនតា គ្របសង្កត់អារម្មណ៍ដែលគួរភ័យខ្លាចបាន ។

៩. អមនុស្សានំ គរុភាវនីយតា ជាបុគ្គលគួរជាទីគោរពនៃអមនុស្សទាំងឡាយ ។

១០. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា មានការប្រព្រឹត្តដ៏សមគួរដល់អរិយធម៌ទាំងឡាយមានការប្រាថ្នាតិចជាដើម ។

គាថាសម្តែងអានិសង្សនៃសោសានិកង្គ

សោសានិកញ្ហិ មរណានុស្សតិប្បភាវា
និទ្ទាគតម្បិ ន ផុសន្តិ បមាទទោសា
សម្បស្សតោ ច កុណបានិ ពហូនិ តស្ស
កាមានុភាវវសគម្បិ ន ហោតិ ចិត្តំ

សំវេគមេតិ វិបុលំ ន មទំ ឧបេតិ
សម្មា អថោ ឃដតិ និព្វុតិមេសមានោ
សោសានិកង្គមិតិនេកគុណាវហត្តា
និព្វាននិន្នហទយេន និសេវិតព្វន្តិ ។

ពិតមែន ទោសគឺសេចក្តីប្រមាទទាំងឡាយ រមែងមិនពាល់ត្រូវសោសានិកភិក្ខុសូម្បីដែលដេកលក់ហើយ ព្រោះមរណានុស្សតិជាដែនកើត មួយទៀត ចិត្តដែលលុះក្នុងអំណាចនៃកាមរាគៈរឿយៗ រមែងមិនមានដល់ភិក្ខុកាលឃើញនូវសាកសពដ៏ច្រើន (នាកាលហេតុយ៉ាងនេះ កាលមាន) លោករមែងដល់នូវសេចក្តីសង្វេគដ៏លើសលុប មិនដល់នូវសេចក្តីប្រមាទ លំដាប់នោះ លោកកាលស្វែងរកនូវព្រះនិព្វាន ជាទីរំលត់ទុក្ខ រមែងប្រឹងប្រែងដោយប្រពៃ (ព្រោះហេតុនោះ) ភិក្ខុអ្នកមានហឫទ័យបង្អោនទៅកាន់ព្រះនិព្វាន គប្បីសេពនូវសោសានិកង្គធុតង្គកុំខានឡើយ ព្រោះនាំមកនូវគុណជាអនេកដូចបានរៀបរាប់មកដូច្នេះឯង ។

១២. អានិសង្សនៃយថាសន្ថតិកង្គធុតង្គ

១. យំ លទ្ធំ តេន តុដ្ឋព្វន្តិ វុត្តោវាទករណំ បានធ្វើតាមឱវាទដែលព្រះមានព្រះភាគត្រាស់ហើយថា បានវត្ថុណាហើយ គប្បីត្រេកអរដោយវត្ថុនោះ ។

២. សព្រហ្មចារិហិតេសតា ជាអ្នកស្វែងរកប្រយោជន៍ដល់សព្រហ្មចារីទាំងឡាយ ។
៣. ហីនប្បណីតវិកប្បបរិច្ចាគោ លះបង់សេចក្តីត្រិះរិះក្នុងសេនាសនៈដែលអន់ និងប្រណីត ។
៤. អនុរោធវិរោធប្បហានំ លះបង់សេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរចេញបាន ។
៥. អត្រិច្ឆតាយ ទ្វារបិទហានំ បិទទ្វារនៃសេចក្តីប្រាថ្នាច្រើន ។
៦. អប្បិច្ឆតាទីនំ អនុលោមវុត្តិតា ប្រព្រឹត្តសមគួរដល់ធុតធម៌មានអប្បិច្ឆតាជាដើម ។

គាថាសម្តែងអានិសង្សនៃយថាសន្តិកង្គ

យំ លទ្ធំ តេន សន្តុដ្ឋោ យថាសន្តិកោ យតិ
និព្វិកប្បោ សុខំ សេតិ តិណសន្ថរកេសុបិ
ន សោ រជ្ជតិ សេដ្ឋម្ហិ ហីនំ លទ្ធា ន កុប្បតិ
សព្រហ្មចារិនវកេ ហិតេន អនុកម្បតិ
តស្មា អរិយតាចិណ្ណំ មុនិបុង្គវវណ្ណិតំ
អនុយុញ្ជេថ មេធាវី យថាសន្តតរាមតន្តិ ។

យថាសន្តិកភិក្ខុ ជាអ្នកសន្តោសដោយវត្ថុដែលខ្លួនបានមក មិនមានសេចក្តីត្រិះរិះ សូម្បីដេកលើកម្រាលស្មៅក៏ជាសុខ ភិក្ខុនោះ

រមែងមិនត្រេកអរក្នុងរបស់ដែលប្រសើរ មិនទោមនស្សព្រោះបានរបស់អន់ តែងអនុគ្រោះនូវសព្រហ្មចារីថ្មីៗ ដោយប្រយោជន៍ ព្រោះហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញា គប្បីប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងសេនាសនៈតាមតែគេចាត់ឱ្យ ដែលព្រះអរិយៈទាំងឡាយប្រព្រឹត្តហើយផង ដែលព្រះសម្ពុទ្ធជាផៅពង្សនៃអ្នកប្រាជ្ញសរសើរហើយផង ។

១៣. អានិសង្សនៃនេសជ្ជិកង្គធុតង្គ

១. សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុញ្ជតោ វិហរតីតិ វុត្តស្ស ចេតសោ វិនិពន្ធស្ស ឧបច្ឆេទនំ ។ កាត់ផ្តាច់នូវគ្រឿងចងរបស់ចិត្តតាមដែលទ្រង់ត្រាស់ទុកថា ភិក្ខុកាលប្រកបរឿយៗ នូវសុខក្នុងការដេក សុខក្នុងការផ្អែក សុខក្នុងការលង់លក់ដូច្នេះជាដើម ។

២. សព្វកម្មដ្ឋានានុយោគសប្បាយតា ការប្រកបរឿយៗ នូវកម្មដ្ឋានគ្រប់សព្វក៏ជាទីសប្បាយ ។

៣. បាសាទិកឥរិយាបថតា មានឥរិយាបថគួរឱ្យជ្រះថ្លា ។

៤. វីរិយារម្ភានុកូលតា មានការប្រព្រឹត្តជាឧបការៈដល់ការប្រារព្ធសេចក្តីព្យាយាម ។

៥. សម្មាបដិបត្តិយា សមុបព្រូហណា ចម្រើនឡើងដោយប្រពៃនៃសម្មាបដិបត្តិ ។

គាថាសម្តែងអានិសង្សនៃនេសជ្ជិកង្គធុតង្គ

អាភុជិត្វាន បល្លង្កំ បណិធាយ ឧជុំ តនុំ
និសីទន្តោ វិកម្បេតិ មារស្ស ហទយំ យតិ
សេយ្យសុខំ មិទ្ធសុខំ ហិត្វា អារទ្ធវីរិយោ
និសជ្ជាភិរតោ ភិក្ខុ សោភយន្តោ តបោវនំ
និរាមិសំ បីតិសុខំ យស្មា សមធិគច្ឆតិ
តស្មា សមនុយុញ្ជេយ្យ ធីរោ នេសជ្ជិកំ វតន្តិ ។

ភិក្ខុកាលអង្គុយពែនភ្នែនតាំងកាយឱ្យត្រង់ រមែងញ៉ាំងហឫទ័យរបស់មារឱ្យញាប់ញ័រ ជាអ្នកមានសេចក្តីព្យាយាមប្រារព្ធហើយ លះបង់នូវសេចក្តីសុខក្នុងការដេក សុខក្នុងការលង់លក់ ជាអ្នកត្រេកអរក្នុងនេសជ្ជិកង្គធុតង្គ កាលញ៉ាំងព្រៃគឺការព្យាយាមឱ្យល្អ រមែងបាននូវបីតិនិងសុខដែលប្រាសចាកអាមិសៈព្រោះហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញាគប្បីប្រកបរឿយៗ នូវនេសជ្ជិកវត្តចុះ ។

ចប់ អានិសង្សធុតង្គតែប៉ុណ្ណោះ ។

សំពត់បំសុកូល ២៣ ប្រភេទ

១. **សោសានិកំ** សំពត់ដែលគេបោះចោលក្នុងព្រៃស្មសាន ។

២. **ចាបណិកំ** សំពត់ដែលគេបោះចោលទៀបទ្វារផ្សារ ។

៣. **រថិយចោឡំ** សំពត់ដែលជនអ្នកប្រាថ្នាបុណ្យបោះចោលតាមផ្លូវនៃរថ ។

៤. **សង្ការចោឡំ** សំពត់ដែលគេបោះចោលត្រង់គំនរសម្រាម ។

៥. **សោត្ថិយំ** សំពត់ដែលគេជូតមន្ទិលនៃគភ៌ហើយបោះចោលដោយប្រាថ្នាសិរីសួស្តី ។

៦. **នហានចោឡំ** សំពត់ដែលពួកគ្រូស្រោចទឹកឱ្យហើយគេបោះចោល ដោយគិតថាជារបស់ចង្រៃ ។

៧. **តិត្ថចោឡំ** សំពត់ដែលគេបោះបង់ចោលត្រង់កំពង់ទឹក ។

៨. **គតប្បច្ចាគតំ** សំពត់ដែលគេទៅកាន់ព្រៃស្មសាន កាលត្រឡប់មកវិញហើយបោះចោល ។

៩. **អគ្គិឌឌ្ឍំ** សំពត់ដែលភ្លើងឆេះ ។

១០. **គោខាយិតំ** សំពត់ដែលសត្វគោទំពាស៊ី ។

១១. **ឧបចិកាខាយិតំ** សំពត់ដែលសត្វកណ្តៀរកោរ ។

១២. **ឧន្ទូរខាយិតំ** សំពត់ដែលសត្វកណ្តុរកាត់ ។

១៣. **អន្តច្ឆិន្នំ** សំពត់ដែលរេចជាយ ហើយគេបោះចោល ។

១៤. **ឧសច្ឆិន្នំ** សំពត់ដែលដាច់ដាចហើយគេបោះចោល ។

១៥. **ធជាហដំ** សំពត់ដែលគេចងធ្វើជាទង់ជ័យហើយគេចចេញទៅ ។

១៦. **ថូបចីវរំ** សំពត់ដែលគេរុំព័ទ្ធដំបូកធ្វើពលីកម្ម ។

១៧. **សមណចីវរំ** សមណចីវរគឺសំពត់របស់ភិក្ខុផងគ្នា ។

១៨. **អាភិសេកិកំ** សំពត់ដែលគេបោះបង់ចោលត្រង់ទីអភិសេកព្រះរាជា ។

១៩. **ឥទ្ធិមយំ** សំពត់ដែលសម្រេចដោយឫទ្ធិ គឺចីវររបស់ឯហិ-ភិក្ខុ ។

២០. **បន្ថិកំ** សំពត់ដែលជ្រុះនៅតាមផ្លូវ ។

២១. **វាតាហដំ** សំពត់ដែលខ្យល់បក់បំប៉ើងនាំទៅ ហើយធ្លាក់ចុះក្នុងទីឆ្ងាយ ។

២២. **ទេវទត្តិយំ** សំពត់ដែលទេវតាប្រគេន ។

២៣. **សាមុទ្ទិយំ** សំពត់ដែលរលកសមុទ្របន្សាត់ផាត់នាំទៅលើគោក ។

ភត្ត ១៤ យ៉ាង

១. **សង្ឃភត្តំ** ភត្តដែលទាយកប្រគេនដល់ភិក្ខុសង្ឃទាំងអស់ ។

២. **ឧទ្ទេសភត្តំ** ភត្តដែលទាយកដៅចំពោះភិក្ខុ ២ - ៣ រូបហើយប្រគេន ។

៣. **និមន្តនំ** ភត្តដែលទាយកពោលនិមន្តហើយប្រគេន ។

៤. **សលាកភត្តំ** ភត្តដែលទាយកប្រគេនតាមស្លាក ។

៥. **បក្ខិកំ** ភត្តដែលទាយកប្រគេនតាមបក្ខ គឺបក្ខខាងរនោច ឬបក្ខខាងខ្នើត ។

៦. **ឧបោសថិកំ** ភត្តដែលទាយកប្រគេនក្នុងថ្ងៃឧបោសថ ។

៧. **បាដិបទិកំ** ភត្តដែលទាយកប្រគេនក្នុងថ្ងៃបន្ទាប់អំពីថ្ងៃឧបោសថ គឺថ្ងៃ ១ រោច ឬ ១ កើត ។

៨. **អាគន្តុកភត្តំ** ភត្តដែលទាយកប្រគេនដល់ភិក្ខុអ្នកទើបមកដល់ ។

៩. **គមិកភត្តំ** ភត្តដែលទាយកប្រគេនដល់ភិក្ខុអ្នកបំប្រុងធ្វើដំណើរ ។

១០. **គិលានភត្តំ** ភត្តដែលទាយកប្រគេនដល់ភិក្ខុអាពាធ ។

១១. **គិលានុបដ្ឋាកភត្តំ** ភត្តដែលទាយកប្រគេនដល់ភិក្ខុអ្នកបម្រើភិក្ខុឈឺ ។

១២. **វិហារភត្តំ** ភត្តដែលទាយកប្រគេនសម្រាប់វិហារ ។

១៣. **ធុរភត្តំ** ភត្តដែលទាយកប្រគេនអស់កាលជានិច្ច (និច្ច-ភត្ត) ។

១៤. **វារភត្តំ** ភត្តដែលទាយកប្រគេនតាមវារៈវេន ។

បច្ចវេក្ខណាវិធី

កុលបុត្រដែលបួសក្នុងព្រះសាសនានេះ ត្រូវសិក្សាក្នុងបច្ចវេក្ខ-ណាវិធីគឺឧបាយសម្រាប់ពិចារណានូវបច្ច័យ ដែលខ្លួនត្រូវអាស្រ័យ ឱ្យចេះចាំស្ទាត់ទាំងបាលី ទាំងសេចក្តីប្រែជាសម្រាយ ។ ឯបច្ច័យ ដែលបព្វជិតត្រូវអាស្រ័យនោះ មាន ៤ គឺ ៖

១) ចីវរប្បច្ច័យ បានដល់សំពត់ដែលបព្វជិតគួរស្លៀកដណ្តប់ ប្រើប្រាស់បាន មានត្រៃចីវរជាដើម ។

២) បិណ្ឌបាតប្បច្ច័យ បានដល់ភោជនាហារដែលបព្វជិតត្រូវ បរិភោគបាន តាំងអំពីវេលាអរុណរះឡើងដរាបដល់ថ្ងៃត្រង់ មាន បាយនំជាដើម ។

៣) សេនាសនប្បច្ច័យ បានដល់ទីសេនាសនៈដែលបព្វជិតត្រូវ អាស្រ័យប្រើប្រាស់បាន មានកុដិ សាលា ជាដើម ។

៤) គិលានប្បច្ច័យ បានដល់ថ្នាំសម្រាប់មនុស្សមានជំងឺ ដែល បព្វជិតត្រូវបរិភោគប្រើប្រាស់បាន មានសប្បិជាដើម ។

ក្នុងបច្ច័យមួយៗ នោះ ពោលដោយបច្ចវេក្ខណៈ មាន ៤ គឺ ៖

១ . ធាតុប្បច្ចវេក្ខណៈ
២ . បដិកូលប្បច្ចវេក្ខណៈ
៣. តង្ខណិកប្បច្ចវេក្ខណៈ
៤ . អតីតប្បច្ចវេក្ខណៈ

បណ្តាបច្ចវេក្ខណៈទាំង ៤ នោះ ធាតុប្បច្ចវេក្ខណៈ គឺឱ្យពិចារណា ក្នុងកាលដែលទទួលនូវបច្ច័យ ៤ ឱ្យឃើញថាត្រឹមតែជាធាតុ ។

ធាតុប្បច្ចវេក្ខណៈ

កាលដែលទទួលនូវចីវរប្បច្ច័យ គប្បីពិចារណាដូច្នេះ

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ
យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ
ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

សំពត់ចីវរឯណានេះ សំពត់ចីវរនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវបិណ្ឌបាតប្បច្ច័យ គប្បីពិចារណាដូច្នេះ

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ
យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច

បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

ចង្ហាន់បិណ្ឌបាតឯណានេះ ចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគនូវចង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវសេនាសនប្បច្ច័យ គប្បីពិចារណាដូច្នេះ

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ

យទិទំ សេនាសនំ តទុបភុញ្ជកោ ច

បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគប្រើប្រាស់ទីសេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវគិលានប្បច្ច័យ គប្បីពិចារណាដូច្នេះ

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ

គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជកោ ច

បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះគ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

បដិកូលបច្ចវេក្ខណៈ

បដិកូលបច្ចវេក្ខណៈនោះ គឺឱ្យពិចារណាក្នុងខណៈដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ ៤ ឱ្យឃើញថាជារបស់បដិកូលគួរខ្ពើម ។

កាលដែលប្រារព្ធនឹងប្រើប្រាស់នូវចីវរ គប្បីពិចារណាដូច្នេះ

សព្វានិ បដិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ

បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។

សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ ក្នុងកាលណាហើយ ក៏ក្លាយជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងឆាន់ចង្ហាន់ គប្បីពិចារណាដូច្នេះថាៈ

សព្វោ បដាយំ បិណ្ឌាចាតោ អជិគុច្ឆនីយោ ឥមំ

បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

ចង្ហាន់បិណ្ឌបាតទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើម ឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ ក្នុងកាលណាហើយ ក៏ក្លាយជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់ នូវសេនាសនប្បច្ច័យ គប្បីពិចារណា ដូច្នេះថា:

សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនីយានិ

ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។

ទីសេនាសនៈទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើម ឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ ក្នុងកាលណាហើយ ក៏ក្លាយជារបស់គួរខ្ពើមរអើមក្រៃពេក ។

សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ អជិគុច្ឆនី-យោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិតគឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងឡាយ ទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់ កាយស្អុយនេះក្នុងកាលណាហើយ ក៏ក្លាយជារបស់គួរខ្ពើមរអើម ក្រៃពេក ។

តង្ខណិកបច្ចវេក្ខណៈ

តង្ខណិកប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណាក្នុងខណៈដែល បរិភោគនូវបច្ច័យ ៤ ។

កាលដែលប្រើប្រាស់នូវបច្ច័យ ៤ នោះ គប្បីពិចារណា ដូច្នេះ

បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតា-តបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោ-បិនប្បដិច្ឆាទនត្ថំ ។ បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរកំណាត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយកំណាត់ទុក ដើម្បីនឹងបិទបាំងនូវអវយវៈដែលធ្វើនូវសេចក្តីខ្មាស់ឱ្យកម្រើក ។

បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ ទវាយ, ន មទាយ, ន មណ្ឌនាយ, ន វិភូសនាយ, យាវទេវ ឥមស្ស កាយស្ស ឋិតិយា, យាបនាយ, វិហឹសុបរតិយា, ព្រហ្មចរិយានុគ្គហាយ, ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ, នវញ្ច វេទនំ ន ឧប្បាទេស្សាមិ, យាត្រា ច មេ ភវិស្សតិ, អនវជ្ជតា ច, ផាសុវិហារោ ចាតិ ។ បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុក ក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានះស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹង

ប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុកដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីនឹងកម្ចាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយធម៌អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំស-មកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវ-ទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។ បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគប្រើប្រាស់នូវទីសេនាសនៈ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវគ្រោះចង្រៃ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិ-សេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។ បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេពគឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុកដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

អតីតប្បច្ចវេក្ខណៈ

អតីតប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណានូវបច្ច័យ ៤ ដែលខ្លួនមិនបានពិចារណា ក្នុងកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានតែក្នុងថ្ងៃនោះ កុំឱ្យអរុណរះឡើងទាន់ គឺដូច្នេះថា: **អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំស-មកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវ-ទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។** សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សរបោម មូស

ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវយវៈដែលធ្វើនូវសេចក្តីខ្មាស់ឱ្យកម្រើក ។

អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ, ន មទាយ, ន មណ្ឌនាយ, ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

ចង្ហាន់បិណ្ឌបាតឯណា ដែលអញមិនបានពិចារណាហើយបរិភោគហើយក្នុងថ្ងៃនេះ ចង្ហាន់បិណ្ឌបាតនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានះស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយដូចស្រ្តីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុាំងជីវិតិន្ទ្រិយឱ្យប្រព្រឹត្តទៅ ដើម្បីនឹងកម្ចាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយធម៌ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញុាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស

មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។

ទីសេនាសនៈឯណា ដែលអញមិនបានពិចារណាហើយ បរិភោគប្រើប្រាស់ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគប្រើប្រាស់កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយកំណត់ទុក ដើម្បីនឹងបន្ទោបង់នូវគ្រោះចង្រៃក្រវាយដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ គិលានប្បច្ចយភេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ

អញបរិភោគកំណាត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

ចប់ បច្ចវេក្ខណាវិធី ។

សីលមានវិគ្រោះថា:

ចិត្តំ សីលតិ សមាធហតិ ឯតេនាតិ សីលំ (គុណជាត) ជាហេតុតាំងមាំនៃចិត្ត (សីលធាតុ សមាធិម្ហិ + អ បច្ច័យ) កត្តុ. ករ.។ **កុសលធម្មេ សីលេន្តិ ឧបធារេន្តិ ឯតេនាតិ សីលំ** (គុណជាត) ជាគ្រឿងទ្រទ្រង់នូវកុសលធម៌ទាំងឡាយ (សីលធាតុ ឧបធារណេ + អ បច្ច័យ) អភិ.គាថា ។


ឧត្តរមានជ័យ
បន្ទាយ
មានជ័យ
សៀមរាប
ព្រះវិហារ
ស្ទឹងត្រែង
រតនគិរី
បាត់ដំបង
កំពង់ធំ
ក្រចេះ
មណ្ឌលគិរី
ប៉ៃលិន
ពោធិ៍សាត់
កំពង់ឆ្នាំង
កំពង់ចាម
ព្រៃវែង
ភ្នំពេញ
កោះកុង
កំពង់ស្ពឺ
ស្វាយរៀង
តាកែវ
កំពត
កណ្ដាល
ព្រះសីហនុ
កែប